**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ**

**និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**


**សារណាបញ្ចប់ការសិក្សា**

# ការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេសនៅកម្ពុជា

ស្រាវជ្រាវ ពីថ្ងៃទី២៣ ខែមីនា ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២


រៀបរៀងដោយ

និស្សិតឈ្មោះ: **ស៊ឹម ឆិត្យពីនី**

**អ៊ុំ សុធី**

សាស្ត្រាចារ្យណែនាំ

**គន្ធា ស្រីសុជាតា**


ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ

ជំនាន់ទី២២

ឆ្នាំចូលសិក្សា ២០១៨

ឆ្នាំសរសេរសារណា ២០២២

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **ស៊ឹម និត្យពីនី** និង **អ៊ុំ សុថី** ជានិស្សិតបរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី២២ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា ២០១៨-២០២២។ ក្នុងនាមពួកខ្ញុំជានិស្សិតជំនាន់ក្រោយដែលជាទំពាំងស្នងឫស្សី និងជាសសរទ្រូងនៃប្រទេសជាតិ យើងខ្ញុំបានធ្វើការសិក្សាស្រាវជ្រាវ និងសរសេរជាសារណា ដើម្បីការពារក្នុងការបញ្ចប់ឆ្នាំសិក្សា ក្រោមប្រធានបទស្តីពី "**ការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេសនៅកម្ពុជា**"។

យើងខ្ញុំទាំងពីរនាក់សូមសម្តែងនូវកតញ្ញូតាធម៌ និងអំណរគុណដ៏ខ្ពង់ខ្ពស់បំផុត ជូនចំពោះអ្នកមានគុណទាំងពីរ ដែលបានចញ្ចឹមបីបាច់ ណែនាំ និងព្រានប្រដៅ តាំងពីថ្ងៃកូនបានចាប់កំណើត រហូតដល់ពួកយើងខ្ញុំបានធំធាត់លូតលាស់ឡើង និងទទួលបានការសិក្សារហូតដល់បានសរសេរសារណា ដើម្បីបញ្ចប់បរិញ្ញាបត្រនេះ ដោយមានការជ្រោមជ្រែងពីលោកទាំងពីរ ទាំងកម្លាំងកាយ និងកម្លាំងចិត្ត។ កូនសូមសន្យាថាកូននឹងចងចាំទង្វើរបស់លោកទាំងពីរជារៀងរហូត។

យើងខ្ញុំទាំងពីរក៏សូមថ្លែងអំណរគុណផងដែរ ចំពោះ អ្នកគ្រូ **គន្ធា ស្រីសុជាតា** ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការពន្យល់ ណែនាំ ផ្តល់ដំបូន្មាន ក៏ដូចជាកែតម្រូវរាល់កំហុសខុសឆ្គង និងភាពខ្វះខាតដែលកើតមានពេលរៀបចំចងក្រងនៅសារណាមួយនេះ។ បើមិនមានវត្តមានរបស់អ្នកគ្រូក្នុងការដឹកនាំនោះទេ សារណាមួយនេះក៏មិនអាចបញ្ចប់ទៅដោយរលូនបែបនេះដែរ។ បន្តទៅទៀតយើងខ្ញុំ សូមអរគុណទៅដល់សាស្ត្រាចារ្យទាំងអស់ដែលបានផ្តល់នូវចំណេះដឹង និងបទពិសោធន៍ជាច្រើនដើម្បីជាយានយន្តនៃប្រភពគំនិតដែលអាចឲ្យយើងខ្ញុំបានតាក់តែង និងស្រាវជ្រាវសារណាមួយនេះឡើងមក។

ជាចុងក្រោយ យើងខ្ញុំទាំងពីរសូមអរគុណ លោកតា លោកយាយ អ៊ុំប្រុស អ៊ុំស្រី ពូមីង បងបងប្អូនញាតិមិត្តជិតឆ្ងាយ ដែលបានផ្តល់នូវកម្លាំងចិត្តក្នុងការសិក្សាស្រាវជ្រាវ ដើម្បីសរសេរនូវសារណាមួយនេះបាន។

ខ្ញុំទាំងពីរ សូមគោរពអរគុណ និងលើកហត្ថប្រួងសួងឲ្យជួបតែពុទ្ធិពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ និងជួបតែសេចក្តីសុខចម្រើនជាដរាបរៀងទៅ។

# អារម្ភកថា

យើងទាំងពីរបានសិក្សា អស់រយៈពេល៤ឆ្នាំ ទៅលើបរិញ្ញាបត្រនីតិសាស្ត្រនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដោយឈានមកដល់ការសិក្សាស្រាវជ្រាវ និងតាក់តែងសារណាដើម្បីបញ្ចប់ឆ្នាំសិក្សា។ យើងទាំងពីរ បានសិក្សាទៅលើប្រព័ន្ធច្បាប់ជាច្រើន នៅក្នុងប្រទេសកម្ពុជា ដែលជាកាតព្វកិច្ចចាំបាច់ក្នុងការយល់ដឹង និងអនុវត្តក្នុងការដោះស្រាយបញ្ហាដែលកើតឡើងក្នុងជីវិតប្រចាំថ្ងៃ។ បន្ថែមពីលើនេះទៅទៀត កំណើនជនបរទេសដែលបានចូលមកក្នុងប្រទេសកម្ពុជា ហាក់មានការកើនឡើងគួរឲ្យកត់សម្គាល់ ដែលជនបរទេសខ្លះមានបំណងក្នុងរស់នៅ និងរៀបអាពាហ៍ពិពាហ៍ជាមួយជនជាតិខ្មែរផងដែរ។ យើងខ្ញុំទាំងពីរសង្កេតឃើញថា ប្រជាពលរដ្ឋកម្ពុជា និងជនបរទេស ហាក់ដូចជាមានភាពស្រពិចស្រពិលទៅលើភារកិច្ចក្នុងការស្នើសុំរៀបអាពាហ៍អាពាហ៍ ក៏ដូចជាឯកសារដែលត្រូវមានភ្ជាប់មកជាមួយ។ ថ្វីត្បិតតែការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជាបរទេសមានភាពប្រហាក់ប្រហែលទៅនឹងការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងពលខ្មែរ តែវាក៏អាចនាំមកនូវបញ្ហាចោទមួយចំនួនដែលពលរដ្ឋខ្មែរ និងជនបរទេសគួរយល់ដឹង។

ដោយមើលឃើញនូវបញ្ហាដែលអាចកើតមានឡើង យើងទាំងពីរបានចូលរួមចំណែកក្នុងការចែករំលែកនូវកិច្ចការស្រាវជ្រាវមួយក្រោមប្រធានបទស្ដីពី "ការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេសនៅប្រទេសកម្ពុជា" មកធ្វើជាកម្មវត្ថុក្នុងការស្រាវជ្រាវដើម្បីបញ្ចប់ការសិក្សាមួយនេះ។ យើងខ្ញុំទាំងពីរនាក់ សង្ឃឹមថាកិច្ចការស្រាវជ្រាវមួយនេះអាចជាជំនួយដល់បងប្អូនប្រជាពលរដ្ឋ និងជនបរទេស ជាពិសេសសិស្សានុសិស្សជំនាន់ក្រោយ ដើម្បីជាឯកសារជំនួយស្មារតីទៅលើអាពាហ៍ពិពាហ៍មួយប្រភេទនេះ ដោយអនុវត្តត្រឹមត្រូវទៅតាមនីតិវិធីច្បាប់ក្នុងប្រទេសកម្ពុជា។

យើងទាំងពីរនាក់ បានធ្វើការសិក្សាស្រាវជ្រាវ និងស្វែងរកឯកសារពាក់ព័ន្ធជាច្រើន មកធ្វើជាមូលដ្ឋានក្នុងការចងក្រងសារណាបញ្ចប់ការសិក្សាមួយនេះ។ យ៉ាងណាមិញការស្រាវជ្រាវលើប្រធានបទនេះ អាចនៅមានចំណុចខ្វះខាត ទាំងពាក្យពេចន៍ អត្ថន័យ និងខ្លឹមសារ ដោយអចេតនាណាមួយ។ ហេតុដូចនេះសូមលោកគ្រូអ្នកគ្រូ សិស្សានុសិស្ស និងមិត្តអ្នកអានទាំងអស់ មេត្តាខន្តីអភ័យទោសចំពោះចំណុចខ្វះខាតនៅក្នុងអត្ថបទមួយនេះផង ហើយយើងខ្ញុំទាំងពីរពេញចិត្តក្នុងការទទួលយកនូវការរិះគន់ក្នុងន័យស្ថាបនាដើម្បីធ្វើការកែលម្អនូវអត្ថបទមួយនេះឲ្យកាន់តែប្រសើរឡើង។ យើងខ្ញុំទាំងពីរក៏សូមថ្លែងអំណរគុណដល់អ្នកដែលបានយកចិត្តទុកដាក់ក្នុងការអានអត្ថបទស្រាវជ្រាវមួយនេះ។

## មាតិកា

**ទំព័រ**

**សេចក្តីផ្តើម** ........ ១
១. លំនាំបញ្ហា ........ ១
២. ចំណោទបញ្ហា ........ ១
៣. គោលបំណងនៃការស្រាវជ្រាវ ........ ២
៤. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ........ ២
៥. សារៈសំខាន់នៃការស្រាវជ្រាវ ........ ២
៦. វិធីសាស្ត្រនៃការស្រាវជ្រាវ ........ ២
៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ២

**ជំពូកទី១**

**ការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេសនៅកម្ពុជា**

**១.១. សណ្ឋាននៃអាពាហ៍ពិពាហ៍** ........ ៣
១.១.១. អាពាហ៍ពិពាហ៍ដែលមិនស្របច្បាប់ ........ ៣
១.១.២. អាពាហ៍ពិពាហ៍ស្របច្បាប់ ........ ៥
**១.២. លក្ខខណ្ឌនៃការរៀបអាពាហ៍ពិពាហ៍** ........ ៥
១.២.១. លក្ខខណ្ឌគ្រឹះនៃការរៀបអាពាហ៍ពិពាហ៍ ........ ៦
១.២.១.១. អាយុ ........ ៦
១.២.១.២. ភេទ ........ ៨
១.២.១.៣. ការព្រមព្រៀង ........ ៨
១.២.១.៤. សមត្ថភាព ........ ៩
១.២.១.៥. ឯកពន្ធភាព ........ ១០
១.២.១.៦ ប្រាក់ចំណូលរបស់ជនបរទេស ........ ១០
១.២.២. លក្ខខណ្ឌទម្រង់នៃការរៀបអាពាហ៍ពិពាហ៍ ........ ១១

១.២.២.១. ការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ................................................ ១១
១.២.២.២. នីតិវិធីនិងបែបបទក្នុងការរៀបអាពាហ៍រវាងពលរដ្ឋខ្មែរនិងជនបរទេសនៅក្នុងប្រទេសកម្ពុជា ១២
**១.៣. មោឃៈភាពនៃអាពាហ៍ពិពាហ៍** ................................................ ១៤
១.៣.១. ករណីដែលចាត់ទុកជាមោឃៈ ................................................ ១៤
១.៣.១.១. មោឃៈភាពអាពាហ៍ពិពាហ៍ដែលគ្មានឆន្ទៈរៀបអាពាហ៍ពិពាហ៍ ................................................ ១៤
១.៣.១.២. មោឃៈភាពអាពាហ៍ពិពាហ៍ដែលពុំបានបំពេញនូវលក្ខខណ្ឌទម្រង់ ................................................ ១៤
១.៣.២. អានុភាពនៃមោឃៈភាពអាពាហ៍ពិពាហ៍ ................................................ ១៥
១.៣.៣. ការដាក់បណ្តឹងទាមទារឱ្យបញ្ជាក់មោឃៈភាពអាពាហ៍ពិពាហ៍ ................................................ ១៥
**១.៤. ការលុបចោលអាពាហ៍ពិពាហ៍** ................................................ ១៥
១.៤.១. ករណីនៃការលុបចោលអាពាហ៍ពិពាហ៍ ................................................ ១៦
១.៤.១.១. ការលុបចោលអាពាហ៍ពិពាហ៍ដែលមិនត្រឹមត្រូវតាមច្បាប់ ................................................ ១៦
១.៤.១.២. ការលុបចោលអាពាហ៍ពិពាហ៍ដោយការគម្រាម ឬឆបោក ................................................ ១៧
១.៤.២. អានុភាពនៃការលុបចោលអាពាហ៍ពិពាហ៍ ................................................ ១៧
១.៤.៣. ការដាក់បណ្តឹងទាមទារឱ្យលុបចោលអាពាហ៍ពិពាហ៍ ................................................ ១៨
**ជំពូកទី២**
**អានុភាពនៃអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ ជាមួយនឹងជនបរទេសនៅកម្ពុជា**
**២.១. សិទ្ធិ និងករណីយកិច្ចរបស់សហព័ទ្ធ** ................................................ ១៩
២.១.១. សិទ្ធិក្នុងការប្រើប្រាស់នាមត្រកូលរបស់ប្តីប្រពន្ធ ................................................ ១៩
២.១.២. សិទ្ធិក្នុងការជ្រើសវិជ្ជាជីវៈ ................................................ ២០
២.១.៣. សិទ្ធិក្នុងការចូលរួមសកម្មភាពសង្គម ................................................ ២១
២.១.៤. ករណីយកិច្ចរួមរស់នឹងគ្នា សហការ និងសង្គ្រោះគ្នាទៅវិញទៅមក ................................................ ២១
**២.២. ទំនាក់ទំនងចំពោះទ្រព្យសម្បត្តិប្តីប្រពន្ធ** ................................................ ២១
២.២.១. ប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា ................................................ ២១
២.២.២. ប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់ ................................................ ២២

២.២.២.១. ទ្រព្យសម្បត្តិដោយឡែក ............................................................ ២៣

២.២.២.២. ទ្រព្យសម្បត្តិរួម ............................................................ ២៣

២.២.២.៣. ការចាត់ចែងទ្រព្យសម្បត្តិរួម និងការអាស្រ័យនៅទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធ .. ២៣

២.២.២.៤. ការទទួលខុសត្រូវដោយសាមគ្គីចំពោះកាតព្វកិច្ច ............................................................ ២៤

**២.៣. ទំនាក់ទំនងចំពោះបុត្តភាព** ............................................................ ២៥

២.៣.១. វិធាននៅក្នុងការកំណត់ឋានៈជាឪពុកម្ដាយ ............................................................ ២៥

២.៣.២. អំណាចមេបា ............................................................ ២៦

**២.៤. ការទទួលបានសញ្ជាតិតាមរយៈការរៀបអាពាហ៍ពិពាហ៍** ............................................................ ២៧

២.៤.១. លក្ខខណ្ឌក្នុងការទាមទារសញ្ជាតិខ្មែរតាមរយៈការរៀបអាពាហ៍ពិពាហ៍ ............................................................ ២៧

២.៤.២. នីតិវិធីនៃការទាមទារសញ្ជាតិខ្មែរតាមរយៈអាពាហ៍ពិពាហ៍ ............................................................ ២៨

**២.៥. ការទទួលបានការរស់នៅដោយស្របច្បាប់នៅកម្ពុជាចំពោះជនបរទេស** ............................................................ ២៩

២.៥.១. លក្ខខណ្ឌដែលត្រូវបំពេញដើម្បីចូលមកស្នាក់នៅកម្ពុជា ............................................................ ៣០

២.៥.២. កាតព្វកិច្ចដែលត្រូវបំពេញ ............................................................ ៣១

២.៥.៣. ការបណ្ដេញចេញពីប្រទេសកម្ពុជា ............................................................ ៣១

**២.៦. ការការពារពីការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍** ............................................................ ៣២

២.៦.១. បញ្ហាជាក់ស្ដែង ............................................................ ៣៣

២.៦.២. វិធានការពារ ............................................................ ៣៤

**សេចក្ដីសន្និដ្ឋាន** ............................................................ ៣៦

**អនុសាសន៍** ............................................................ ៣៧

**គន្ថនិទ្ទេស**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

នាបច្ចុប្បន្ននេះ គឺជាយុគសម័យជឿនលឿនមួយ ដែលប្រទេសជាច្រើននៅលើពិភពលោកមានភាពងាយស្រួលក្នុងការប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមកលើគ្រប់វិស័យ។ ក្រៅពីជាយុគសម័យដែលជឿនលឿនលើគ្រប់វិស័យហើយនោះ ក៏ជាសម័យមួយដែលបើកទូលាយ និងមានសមភាពយេនឌ័រនៅក្នុងសង្គមផងដែរ ដែលមានន័យថាគ្រប់បុរស ឬស្ត្រីមានសិទ្ធិស្មើៗគ្នានៅក្នុងសង្គម និងជីវភាពរស់នៅប្រចាំថ្ងៃ។ ដោយសារតែមានភាពងាយស្រួលក្នុងការប្រាស្រ័យទាក់ទងគ្នាពីប្រទេសមួយទៅប្រទេសមួយផ្សេងទៀតបែបនេះហើយ ទើបប្រទេសនីមួយៗនៅជុំវិញពិភពលោក មានចម្រុះទៅដោយជាតិសាសន៍ផ្សេងៗជាច្រើនចូលមកស្នាក់នៅ ឬមកបំពេញភារកិច្ច ឬកំសាន្តលេងជាដើម។ បើយើងក្រឡេកមកមើលប្រទេសកម្ពុជានាពេលបច្ចុប្បន្នវិញ លំហូរនៃការចូលមករបស់ជាតិសាសន៍ដទៃរឹតតែមានការកើនឡើងគួរឱ្យកត់សម្គាល់។ ការកើនឡើងនៃចំនួនជនបរទេសចូលមកប្រទេសកម្ពុជាគឺជាសញ្ញាមួយដែលបានបង្ហាញថាប្រទេសកម្ពុជាកំពុងតែត្រូវបានស្គាល់ និងមានវត្តមានលើឆាកអន្តរជាតិជាថ្មីម្តងទៀត បន្ទាប់ពីបានរួចផុតពីភាពសាហាវយង់ឃ្នងនៃរបបកម្ពុជាប្រជាធិបតេយ្យ។ លើសពីនេះទៅទៀត ការហូរចូលរបស់ជនបរទេសមកកម្ពុជាក៏ជាកត្តាមួយដែលនាំឱ្យសេដ្ឋកិច្ចមានការរីកចំរើន រីឯទំនាក់ទំនងនៅក្នុងសង្គមក៏មានភាពទូលំទូលាយ ជាពិសេសការជ្រើសរើសគូស្រករដែលជាជនបរទេសរឹតតែមានការកើនឡើង។

នៅប្រទេសកម្ពុជាបានបើកសិទ្ធិដល់បុរស និងនារីក្នុងការជ្រើសរើសគូស្រករបានដោយសេរីដោយមិនប្រកាន់ទៅលើជាតិ សាសន៍ និងពណ៌សម្បុរនោះឡើយ។ ចំពោះការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេសនៅប្រទេសកម្ពុជា មាននីតិវិធី និងដំណាក់កាលមួយចំនួនដូចជា ការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការជូនដំណឹងជាសាធារណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និងការចុះបញ្ជីនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានជាដើម។

យ៉ាងណាមិញ ទោះបីជាមានការកើនឡើងនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស ក៏យើងសង្កេតឃើញថា ការរៀបអាពាហ៍ពិពាហ៍ទាំងនោះហាក់ដូចមាននូវចំណុចខ្វះខាតមួយចំនួនដែលធ្វើឱ្យអាពាហ៍ពិពាហ៍ទាំងនោះបាត់បង់នូវអានុភាព និងមិនស្របច្បាប់។

## ២. ចំណោទបញ្ហា

ដោយមើលឃើញទៅលើទិដ្ឋភាពដែលបានកើតឡើងសព្វថ្ងៃ នៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស ដូច្នេះហើយ តើត្រូវធ្វើដូចម្តេចដើម្បីធ្វើឱ្យអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេសក្លាយជាអាពាហ៍ពិពាហ៍មួយដែរស្របច្បាប់? តើអាពាហ៍ពិពាហ៍ដែលស្របច្បាប់ផ្តល់អានុភាពដូចម្តេចខ្លះដល់សហព័ទ្ធ?

តើសហព័ទ្ធដែលជាជនបរទេស ត្រូវបំពេញលក្ខខណ្ឌអ្វីខ្លះ ដើម្បីទទួលបានអានុភាព តាមរយៈអាពាហ៍ពិពាហ៍របស់ខ្លួន?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការធ្វើការសិក្សាស្រាវជ្រាវសារណាមួយនេះ មានគោលបំណង ដើម្បីស្រាវជ្រាវឱ្យបានស៊ីជម្រៅទៅលើបញ្ហា ផលប៉ះពាល់ និងដំណោះស្រាយដែលកើតមានក្នុងការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស ដោយស្វែងយល់អំពីលក្ខខណ្ឌផ្សេងៗនៃការរៀបអាពាហ៍ពិពាហ៍ ទិដ្ឋភាពច្បាប់ដែលពាក់ព័ន្ធ នីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍ សេចក្តីសន្និដ្ឋាន និងអនុសាសន៍ដើម្បីធ្វើការកែតម្រូវចំពោះបញ្ហាទាំងឡាយ។

## ៤. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

សារណានេះ មានដែនកំណត់គ្របដណ្តប់ទៅលើទិដ្ឋភាពច្បាប់ ក៏ដូចជាការអនុវត្តច្បាប់ដែលទាក់ទងទៅនឹងការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេសនៅប្រទេសកម្ពុជា ហើយការសិក្សាស្រាវជ្រាវនេះមានវិសាលភាពក្នុងក្របខណ្ឌនៃច្បាប់កម្ពុជា ដែលរួមមានក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា អនុក្រឹត្យ និងប្រកាសផ្សេងៗទៀតផងដែរ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

សារៈប្រយោជន៍នៃប្រធានបទស្រាវជ្រាវនេះ ធ្វើជាជំនួយដល់អ្នកសិក្សាទាំងឡាយ យល់ដឹងពីអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស នីតិវិធីច្បាប់ លក្ខខណ្ឌផ្សេងៗ អានុភាពនៃការរៀបអាពាហ៍ពិពាហ៍ និងមោឃៈភាពនៃអាពាហ៍ពិពាហ៍ផងដែរ។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវមួយនេះ គឺពឹងផ្អែកទៅលើ ការសុំណែនាំពិសាស្ត្រាចារ្យដឹកនាំសារណា យោបល់ពីសិស្សច្បង មេធាវី ឯកសារគតិយុត្តិ (ច្បាប់ អនុក្រឹត្យ ប្រកាស និងសេចក្តីណែនាំដែលទាក់ទងនឹងអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស។ ឯកសារទាំងអស់នេះ សុទ្ធសឹងតែមានសុពលភាព អនុវត្តនៅក្នុងព្រះរាជាណាចក្រកម្ពុជាយើងសព្វថ្ងៃ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដើម្បីឱ្យកាន់តែយល់ច្បាស់ទៅលើការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស សារណាមួយនេះបានបែងចែកជា ២ជំពូក។ ជំពូកទី១ បកស្រាយអំពី ការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេសនៅកម្ពុជា។ ចំណែកជំពូកទី២ បកស្រាយអំពី អានុភាពនៃអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស ដោយរួមបញ្ចូលជាមួយឧបសម្ព័ន្ធផងដែរ។

# ជំពូកទី១

# ការរៀបអាពាហ៍ពិពាហ៍រវាង
# ពលរដ្ឋខ្មែរ និងជនបរទេសនៅ
# កម្ពុជា

# ជំពូកទី១

# ការរៀបអាពាហ៍ពិពាហ៍ខាងពលរដ្ឋខ្មែរ និងជនបរទេសនៅកម្ពុជា

## ១.១. សណ្ឋាននៃអាពាហ៍ពិពាហ៍

យោងតាមមាត្រា ៣ នៃច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩ បានផ្ដល់និយមន័យអាពាហ៍ពិពាហ៍ ថាគឺជាកិច្ចសន្យាដ៏ឱឡារិកមួយដែលធ្វើឡើងដោយបុរសម្នាក់ និងស្ត្រីម្នាក់ដែលប្ដេជ្ញាថាខ្លួននឹងរួមសមគ្គសង្វាសជាមួយគ្នាតាមបញ្ញត្តិច្បាប់ ហើយមិនអាចរំលាយទៅវិញបានតាមទំនើងចិត្តឡើយ។ មានន័យថានេះគឺជាចំណងគតិយុត្ត និងប្រពៃណីដែលបុរស និងស្ត្រីបានធ្វើឡើងយ៉ាងឱឡារិកដែលចង់បង្ហាញថាពួកគេទាំងពីរនឹងរួមរស់ជាមួយគ្នាជាសហព័ទ្ធស្របច្បាប់។ ទោះបីជាមាត្រា ៣ នៃច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និងគ្រួសារឆ្នាំ១៩៨៩ ត្រូវបាននិរាករណ៍ តាមរយៈការចូលជាធរមាននៃច្បាប់ស្ដីពីការអនុវត្តក្រមរដ្ឋប្បវេណី ឆ្នាំ២០១១[1] ក៏ដោយ ក៏និយមន័យ នៃអាពាហ៍ពិពាហ៍ ត្រូវបានយល់ឃើញដូចខ្លឹមសារនៃមាត្រានេះ បានយ៉ាងទូលំទូលាយនៅក្នុង វិស័យយុត្តិធម៌កម្ពុជា។

តាមទស្សនៈសង្គមទូទៅនៅពេលដែលគេនិយាយអំពីពាក្យថា «ប្ដីប្រពន្ធ» គេតែងតែនឹកឃើញដល់បុរស និងនារី ដែលបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា និងបានរួមរស់ជាមួយគ្នាជាគ្រួសារតែមួយ។ នៅប្រទេសកម្ពុជា ក៏ដូចជាប្រទេសផ្សេងៗជុំវិញពិភពលោក នៅពេលដែលបុរស និងនារី ដែលមានបំណងចង់រួមរស់ជាមួយគ្នា តែងតែប្រារព្ធពិធីរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីទំនៀមទម្លាប់ខ្មែរ ដែលមានតាំងពីបុរាណមកម្ល៉េះ។ ប៉ុន្តែចំពោះប្រទេសកម្ពុជាត្រឹមតែការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីបែបនេះ ហាក់បីដូចជាពុំទាន់គ្រប់គ្រាន់ទៅតាមផ្លូវច្បាប់នៅឡើយទេ ប្រសិនបើយើងពិចារណាទៅលើមាត្រា ៩៥៥ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា។ តាមមាត្រាខាងលើនេះ យើងឃើញថា នៅសង្គមកម្ពុជា អាពាហ៍ពិពាហ៍អាចត្រូវបានបែងចែកជា ២ សណ្ឋានគឺ អាពាហ៍ពិពាហ៍ដែលមិនស្របច្បាប់ និងអាពាហ៍ពិពាហ៍ស្របច្បាប់។

### ១.១.១. អាពាហ៍ពិពាហ៍ដែលមិនស្របច្បាប់

អាពាហ៍ពិពាហ៍ដែលមិនស្របច្បាប់ គឺជាស្ថានភាពដែលបុរស និងនារី រួមរស់ជាមួយគ្នា ឬបានរៀបអាពាហ៍ពិពាហ៍តាមប្រពៃណី ឬធ្វើជាពិធីសែនព្រេនដូនតាជាដើម ប៉ុន្តែ ពុំបានចុះសំបុត្រអាពាហ៍ពិពាហ៍ ឬអេតាស៊ីវិលជាមួយគ្នាឡើយ។ ស្ថានភាពនៃអាពាហ៍ពិពាហ៍បែបនេះ យើងអាចនិយាយបានថា វាមានភាពងាយស្រួលដោយមិនមានការបំពេញបែបបទច្រើន នៅពេលដែលមានបំណងរួមរស់ជាមួយគ្នា ហើយការបញ្ចប់ទំនាក់ទំនងក៏ពុំចាំបាច់ត្រូវការ នីតិវិធីតាមផ្លូវតុលាការដើម្បីចាត់ចែងតាមផ្លូវច្បាប់នោះដែរ គឺត្រឹមតែការព្រម

[1] ច្បាប់ស្ដីពីការអនុវត្តក្រមរដ្ឋប្បវេណី, ៣១ ឧសភា ២០១១, មាត្រា៧៨

ព្រៀងរបស់ភាគី នឹងមានភាពគ្រប់គ្រាន់ហើយ។ យើងសង្កេតឃើញថាស្ថានភាពបែបនេះ តែងតែកើតមានឡើង មិនថានៅប្រទេសកម្ពុជា ឬនៅតាមបណ្តាប្រទេសជឿនលឿននោះទេ។

ជាទូទៅ អាពាហ៍ពិពាហ៍មិនស្របច្បាប់នៅកម្ពុជា មានការយល់ឃើញថា ជាទំនាក់ទំនងរវាងបុរស និង នារី តាមបែបអនីតិសង្វាស។ និយមន័យ ឬ មូលដ្ឋានក្នុងការកំណត់ជាទំនាក់ទំនងនៃអនីតិសង្វាសនៅកម្ពុជាបច្ចុប្បន្ននេះ មិនទាន់មានការកំណត់ជាក់លាក់តាមផ្លូវច្បាប់នៅឡើយទេ។ ប៉ុន្តែ នៅក្នុងផ្នត់គំនិតទូទៅ អនីតិសង្វាស មានការយល់ឃើញថា ជាការរួមសមគ្គសង្វាសតាមព្រឹត្តន័យ ដែលមានន័យថាគឺជាស្ថានភាពដែលបុរស និងនារី បានរួមរស់ជាមួយគ្នាជាប្តីប្រពន្ធ ដោយពួកគេបានរៀបអាពាហ៍ពិពាហ៍ ឬមិនបានរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីជាមួយគ្នា ដោយពុំបានចុះសំបុត្រអាពាហ៍ពិពាហ៍ ឬអេតាស៊ីវិលតាមផ្លូវច្បាប់នោះទេ។ យើងសង្កេតឃើញថា ការរស់នៅបែបជាអនីតិសង្វាសរវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរ ឬ រវាងបរទេស និង ពលរដ្ឋខ្មែរ នៅក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ននេះ ហាក់បីដូចជាមានការកើនឡើង ដែលប្រហែលជាអាចបណ្តាលមកពីការឆ្លងវប្បធម៌បរទេស ឬ ការបើកទូលាយនូវសិទ្ធិសេរីភាពក្នុងការជ្រើសរើសគូរស្រករជាដើម។

យើងសង្កេតឃើញថា ការរស់នៅបែបជាអនីតិសង្វាសរវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរ ឬ រវាងបរទេស និងពលរដ្ឋខ្មែរ នៅក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ននេះ ហាក់បីដូចជាមានការកើនឡើង ដែលប្រហែលជាអាចបណ្តាលមកពីការឆ្លងវប្បធម៌បរទេស ឬ ការបើកទូលាយនូវសិទ្ធិសេរីភាពក្នុងការជ្រើសរើសគូរស្រករជាដើម។ ទោះបីជាមានការរៀបអាពាហ៍ពិពាហ៍តាមទំនៀមទម្លាប់សាសនា ឬតាមប្រពៃណីក៏ដោយ ក៏ត្រូវបានគេចាត់ទុកត្រឹមតែជាភាពត្រឹមត្រូវមួយតាមផ្នែកសីលធម៌តែប៉ុណ្ណោះ។ ត្រឹមតែការរៀបអាពាហ៍ពិពាហ៍បែបនេះពុំទាន់មានភាពត្រឹមត្រូវតាមផ្នែកច្បាប់នៅឡើយទេ។ ម្យ៉ាងទៀត ទំនាក់ទំនងនេះ នឹងនាំឱ្យបាត់បង់នូវអានុភាពគតិយុត្តដូចជា សិទ្ធិ និងករណីយកិច្ចជាសហព័ទ្ធតាមផ្លូវច្បាប់។ លើសពីនេះទៅទៀត ទោះបីជាបុរស និងនារីដែលស្ថិតនៅក្នុងទំនាក់ទំនងអនីតិសង្វាស បានដាក់ពាក្យបណ្តឹងលែងលះ ឬ ពាក្យសុំលែងលះមកកាន់តុលាការ ក៏តុលាការមិនអាចទទួលយកពាក្យបណ្តឹងលែងលះ ឬ ពាក្យសុំលែងលះ មកជំនុំជម្រះបាននោះទេ ព្រោះទំនាក់ទំនងនេះមិនមែនស្ថិតនៅក្នុងចំណងគតិយុត្តនៃអាពាហ៍ពិពាហ៍នោះទេ ហើយតុលាការត្រូវធ្វើការ លើកចោលបណ្តឹងលែងលះ និង ពាក្យសុំលែងលះ។ ហេតុដូច្នេះ ប្រសិនបើភាគីទាំងសងខាងមានបំណងចង់បញ្ចប់នូវទំនាក់ទំនងជាអនីតិសង្វាស នោះពួកគេគ្រាន់តែព្រមព្រៀងគ្នា ឬរស់នៅផ្សេងពីគ្នាជាការស្រេច ហើយទំនាក់ទំនងដែលជាអនីតិសង្វាសនេះអាចបញ្ចប់ទៅបានគ្រប់ពេលវេលា។

### ១.១.២. អាពាហ៍ពិពាហ៍ស្របច្បាប់

អាពាហ៍ពិពាហ៍ដែលត្រូវបានចាត់ទុកថាជាអាពាហ៍ពិពាហ៍ស្របច្បាប់ គឺជាអាពាហ៍ពិពាហ៍ដែលបានបំពេញតាមលក្ខខណ្ឌគ្រឹះ និងលក្ខខណ្ឌទម្រង់ តាមការកំណត់នៅក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។ ខ្លឹមសារលម្អិតអំពីលក្ខខណ្ឌគ្រឹះ និងលក្ខខណ្ឌទម្រង់ នឹងមានពន្យល់ចាប់ពីផ្នែក ១.២ លក្ខខណ្ឌនៃការរៀបអាពាហ៍ពិពាហ៍ ប៉ុន្តែ នៅទីនេះសូមកត់សម្គាល់ថា អាពាហ៍ពិពាហ៍ស្របច្បាប់ ដែលបានបំពេញតាមលក្ខខណ្ឌទាំងនេះរួចហើយ នឹងនាំឱ្យអាពាហ៍ពិពាហ៍នោះមានអានុភាពត្រឹមត្រូវតាមច្បាប់។ ដូចនេះ ប្តីប្រពន្ធដែលជាសហព័ទ្ធនឹងគ្នាពុំអាចបញ្ចប់ទំនាក់ទំនងនៃចំណងអាពាហ៍ពិពាហ៍តាមទំនើងចិត្តបានទេ។ ចំណងអាពាហ៍ពិពាហ៍ស្របច្បាប់ មានលក្ខណៈស្មុគស្មាញដែលចាំបាច់តម្រូវឱ្យតុលាការត្រូវអ្នកដោះស្រាយ និងចាត់ចែងដើម្បីទទួលបានយុត្តិធម៌តាមផ្លូវច្បាប់។

ជាទូទៅ អាពាហ៍ពិពាហ៍ស្របច្បាប់ ជាអាពាហ៍ពិពាហ៍ដែលមានការចុះសំបុត្រអាពាហ៍ពិពាហ៍ ឬ ចុះអេតាស៊ីវិល ដែលកើតមកពីការបំពេញលក្ខខណ្ឌគ្រឹះ និងលក្ខខណ្ឌទម្រង់នៃការរៀបអាពាហ៍ពិពាហ៍។ ការចុះសំបុត្រអាពាហ៍ពិពាហ៍ ឬចុះអេតាស៊ីវិល គឺជាផ្នែកមួយដ៏សំខាន់នៅក្នុងអាពាហ៍ពិពាហ៍ដែលត្រូវបានគេមើលរំលង។ ការមិនចុះសំបុត្រអាពាហ៍ពិពាហ៍ ឬមិនចុះអេតាស៊ីវិល គឺជាហេតុដែលនាំឱ្យមានផលវិបាកនៅពេលទំនាក់ទំនងរវាងប្តីប្រពន្ធត្រូវបានបញ្ចប់ដោយភាគីពុំអាចព្រមព្រៀងគ្នាបាន នោះតម្រូវឱ្យមានការពិចារណាយ៉ាងស៊ុជម្រៅចំពោះទ្រព្យសម្បត្តិដែលភាគីបានអះអាងថាជាទ្រព្យរបស់ខ្លួនដោយភ្ជាប់ជាមួយនឹងភស្តុតាងដែលគួរឱ្យទុកចិត្ត។

ហេតុដូចនេះ ការចុះសំបុត្រអាពាហ៍ពិពាហ៍ ឬចុះអេតាស៊ីវិលគឺជានីតិវិធីដែលត្រឹមត្រូវតាមច្បាប់ ដោយបុរស និងនារី ដែលស្ម័គ្រចិត្តយកគ្នាជាប្តីប្រពន្ធដោយត្រូវទៅចុះបញ្ជីនៅចំពោះមុខមន្ត្រីអត្រានុកូលខាងលំនៅដ្ឋានរបស់នារីព្រមទាំងមានសាក្សីដែលជានីតិជនចំនួនពីររូបផងដែរ។ លើសពីនេះទៅទៀត ការកំណត់ដោយច្បាប់បែបនេះមិនត្រឹមតែធ្វើឱ្យអាពាហ៍ពិពាហ៍មានអានុភាពគ្រប់គ្រាន់តាមច្បាប់ប៉ុណ្ណោះទេ ព្រមទាំងផ្តល់នូវអត្ថប្រយោជន៍ដល់ភាគីដែលជាសហព័ទ្ធក្នុងការតតាំងចំពោះតតិយជនផងដែរ។

### ១.២. លក្ខខណ្ឌនៃការរៀបអាពាហ៍ពិពាហ៍

ជាគោលការណ៍ ការរៀបអាពាហ៍ពិពាហ៍នៅក្នុងវិសាលភាពនៃនីតិអន្តរជាតិឯកជន តែងតែ ពិចារណាក្នុងការជ្រើសយកច្បាប់របស់ប្រទេសណាមួយមកធ្វើជាមូលដ្ឋាន ដើម្បីឱ្យចំណងអាពាហ៍ពិពាហ៍ត្រូវបានបង្កើតឡើងតាមច្បាប់នោះ ដោយពិនិត្យទៅលើដូចជា ច្បាប់សញ្ជាតិរបស់ ភាគី ច្បាប់លំនៅឋានរបស់ភាគី ឬ ច្បាប់នៃទីកន្លែងប្រព្រឹត្តិអាពាហ៍ពិពាហ៍។ ដោយឡែក ការប្រព្រឹត្តិទៅនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេសនៅកម្ពុជា ត្រូវគោរពទៅតាមលក្ខខណ្ឌនៃការរៀបអាពាហ៍ពិពាហ៍ ដោយយកច្បាប់ និងបទដ្ឋានគតិយុត្ត

ផ្សេងៗរបស់កម្ពុជាធ្វើជាមូលដ្ឋាន ដែលនេះជាការចង្អុលបង្ហាញយ៉ាងច្បាស់នៅក្នុងមាត្រា ៣៣ នៃអនុក្រឹត្យលេខ ១០៣ អនក្រ.បក ស្តីពី អត្រានុកូលដ្ឋាន ឆ្នាំ២០០០។

ច្បាប់ និងបទដ្ឋានគតិយុត្តិដែលពាក់ព័ន្ធនឹងលក្ខខណ្ឌគ្រឹះ និងលក្ខខណ្ឌទម្រង់នៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេសត្រូវយោងតាមក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧ ដូចទៅនឹងការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរដែរ។ ប៉ុន្តែ ខ្លឹមសារលម្អិតនៃបទដ្ឋានគតិយុត្តិដែលពាក់ព័ន្ធនឹងលក្ខខណ្ឌទម្រង់វិញត្រូវបានកំណត់ជាពិសេសនៅក្នុងអនុក្រឹត្យស្តីពី ការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស ឆ្នាំ២០០៨។

### ១.២.១. លក្ខខណ្ឌគ្រឹះនៃការរៀបអាពាហ៍ពិពាហ៍

លក្ខខណ្ឌគ្រឹះនៃការរៀបអាពាហ៍ពិពាហ៍ គឺជាលក្ខខណ្ឌដ៏សំខាន់មួយពាក់ព័ន្ធទៅនឹងលក្ខណៈសម្បត្តិរបស់បុគ្គលដែលនឹងរៀបអាពាហ៍ពិពាហ៍ ដោយការកំណត់ដោយច្បាប់បែបនេះដើម្បីឱ្យមានភាពត្រឹមត្រូវ និងរក្សានូវសណ្តាប់ធ្នាប់ល្អនៅក្នុងសង្គម។ ម្យ៉ាងវិញទៀតការកំណត់បែបនេះគឺជាវិធីមួយដើម្បីការពារដល់បុគ្គលដែលនឹងរៀបអាពាហ៍ពិពាហ៍ឱ្យចៀសផុតពីការឆបោក ឬការកេងប្រវ័ញ្ចផ្សេងៗពីសំណាក់ភាគីម្ខាងទៀតដើម្បីផលប្រយោជន៍ណាមួយ។

ហេតុដូចនេះហើយ បុគ្គលដែលជាជនបរទេស និងជាពលរដ្ឋខ្មែរដែលមានបំណងរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាគឺដាច់ខាតត្រូវគោរពនូវលក្ខខណ្ឌគ្រឹះខាងក្រោមនេះ ដើម្បីទទួលបាននូវអាពាហ៍ពិពាហ៍មួយដែលត្រឹមត្រូវ ព្រមទាំងទទួលស្គាល់ និងការការពារពីច្បាប់នៅកម្ពុជា។ ការមិនបានបំពេញនូវលក្ខខណ្ឌគ្រឹះណាមួយគឺជាហេតុដែលនឹងនាំឱ្យអាពាហ៍ពិពាហ៍នោះ ពុំអាចកើតឡើងបាន។

#### ១.២.១.១. អាយុ

##### ក. កម្រិតអប្បបរមា

ក្រមរដ្ឋប្បវេណីបានកំណត់នូវអាយុយ៉ាងជាក់លាក់ ដែលអាចអនុញ្ញាតឱ្យរៀបអាពាហ៍ពិពាហ៍បាន ជាគោលការណ៍ កំណត់យកអាយុនីតិភាពរវាងបុរស និង នារី។[2] ជាគោលការណ៍ នីតិភាពនៃរូបវន្តបុគ្គល គឺអាយុចាប់ពី ១៨ ឆ្នាំឡើងទៅ។[3] នៅត្រង់មាត្រា ៩៤៨។ មានន័យថា ចំពោះភាគីដែលបានដល់នីតិភាពហើយ គឺអាចរៀបអាពាហ៍ពិពាហ៍បាន។ ទន្ទឹមនឹងនេះ អនីតិជននឹងទទួលបាននូវអគ្គាធីនភាព នៅក្នុងករណីពីរយ៉ាងគឺ[4]៖

- តាមដីកាសម្រេចរបស់តុលាការ ដោយផ្អែកតាមពាក្យសុំរបស់អនីតិជនដែលបានដល់អាយុ ១៦ឆ្នាំ។

[2] ក្រមរដ្ឋប្បវេណី, ៨ ធ្នូ ២០០៧, មាត្រា៩៤៨
[3] ក្រមរដ្ឋប្បវេណី, ៨ ធ្នូ ២០០៧, មាត្រា១៧
[4] ក្រមរដ្ឋប្បវេណី, ៨ ធ្នូ ២០០៧, មាត្រា២៣

- តាមរយៈការរៀបអាពាហ៍ពិពាហ៍របស់អនីតិជននោះ។

ឧទាហរណ៍ (១)៖ កញ្ញា (ក) មានអាយុ ១៦ឆ្នាំ ហើយនាងមានសមត្ថភាពអាចទ្រទ្រង់ជីវភាពរស់នៅដោយខ្លួនឯងបាន ពោលគឺមិនចាំពឹងពាក់ឪពុកម្តាយរបស់នាងឡើយ។ នៅក្នុងករណីនេះ ប្រសិនបើនាងចង់បានអត្តាធីនភាព នាងត្រូវដាក់ពាក្យសុំទៅតុលាការនៃលំនៅដ្ឋានរបស់នាង ដើម្បីស្នើសុំអត្តាធីនភាព (យោងតាមច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង)។ ម្យ៉ាងទៀត ក្រោយពីនាងទទួលបាននូវអត្តាធីនភាពហើយ ប្រសិនបើនាងចង់រៀបអាពាហ៍ពិពាហ៍ គឺនាងមិនចាំបាច់ស្នើសុំការអនុញ្ញាតយល់ព្រមពីឪពុកម្តាយរបស់នាងទេ។

ឧទាហរណ៍ (២)៖ កញ្ញា (ក) មានអាយុ ១៦ឆ្នាំ។ នាងបានរៀបអាពាហ៍ពិពាហ៍ជាមួយនឹងលោក (ខ) ដោយមានការយល់ព្រមពីឪពុកម្តាយ របស់នាង។ ក្រោយពីបានចុះអេតាស៊ីវិលរួចហើយ កញ្ញា (ក) ទទួលបាននូវអត្តាធីនភាពដោយស្វ័យប្រវត្តិ ដោយមិនចាំបាច់ស្នើសុំដីកាសម្រេចពីតុលាការឡើយ។ ឧបមាថា ៦ខែក្រោយ លោក (ខ) បានស្លាប់បាត់បង់ជីវិតដោយសារគ្រោះថ្នាក់ចរាចរណ៍។ ក្នុងករណីបែបនេះ លោកស្រី (ក) នាងមានអាយុមិនដល់ ១៧ ឆ្នាំទេ ក៏ប៉ុន្តែ ប្រសិនបើនាងចង់រៀបអាពាហ៍ពិពាហ៍ជាថ្មីម្តងទៀត នាងអាចសម្រេចចិត្តធ្វើបានដោយមិនចាំបាច់ស្នើសុំការយល់ព្រមពីឪពុកម្តាយនាងទៀតទេ។

ជាងនេះទៅទៀត ប្រសិនបើភាគីម្ខាងទៀតនៃអាពាហ៍ពិពាហ៍ គឺជាអនីតិជន៖

- អនីតិជនដែលមានអាយុចាប់ពី ១៦ឆ្នាំឡើងទៅនោះ ភាគីដែលជាអនីតិជន ត្រូវតែមានការយល់ព្រមពីអ្នកដែលមានអំណាចមេបា ឬអាណាព្យាបាលសម្រាប់អនីតិជន។ ម្យ៉ាងវិញទៀត នៅក្នុងករណីដែលអ្នកមានអំណាចមេបាន ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន បានបដិសេធមិនអនុញ្ញាតយល់ព្រមឱ្យអនីតិជនរៀបអាពាហ៍ពិពាហ៍ ដោយគ្មានមូលហេតុសមរម្យ អនីតិជនអាចទាមទារទៅតុលាការឱ្យសម្រេចសេចក្តីជំនួសបានដែលការយល់ព្រមនោះបានត្រូវអនុលោមតាមមាត្រា ៩៥៣ កថាខណ្ឌទី ៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។ ក្នុងករណីនេះ តុលាការនៃលំនៅឋានរបស់អនីតិជន គឺជាតុលាការមានសមត្ថកិច្ច ហើយសម្រេចសេចក្តីជាដីកាសម្រេច ដោយផ្អែកតាមច្បាប់ស្តីពីនីតិវិធីរឿងក្តីដែលមិនមែនជាបណ្តឹង។

ឧទាហរណ៍ (១)៖ កញ្ញា (ក) មានអាយុ ១៦ឆ្នាំ បានស្រឡាញ់លោក (ខ) ដែលមានអាយុ ១៩ឆ្នាំ ហើយមានបំណងរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា។ នៅក្នុងករណីនេះ ដើម្បីរៀបការបាន ត្រូវមានការអនុញ្ញាតយល់ព្រមពីឪពុកម្តាយរបស់ កញ្ញា (ក) សិន។ ប្រសិនបើមានត្រឹមការយល់ព្រមពីឪពុក ឬម្តាយរបស់កញ្ញា (ក) តែម្ខាងក៏មិនបានដែរ។ ប៉ុន្តែ ប្រសិនបើឪពុក និងម្តាយ របស់កញ្ញា (ក) បានបដិសេធក្នុងរឿងនេះ កញ្ញា (ក) អាចមានជម្រើសចំនួន ៣ យ៉ាង៖

ជម្រើសទី១៖ ត្រូវរង់ចាំឱ្យរូបនាងមានអាយុ ១៨ឆ្នាំសិន។

ជម្រើសទី២៖ ត្រូវស្នើសុំអត្តាធីនភាពពីតុលាការ។

ជម្រើសទី៣៖ ត្រូវស្នើសុំឱ្យតុលាការសម្រេចសេចក្តី ជំនួសការយល់ព្រមរបស់ឪពុកម្តាយនាង។

**ខ. កម្រិតអតិបរមា**

ពលរដ្ឋខ្មែរ និងជនបរទេសណា ដែលមានបំណងរៀបអាពាហ៍ពិពាហ៍ជាមួយគ្នានៅប្រទេសកម្ពុជា ចាំបាច់ត្រូវគោរពតាមលក្ខខណ្ឌគ្រឹះ និងលក្ខខណ្ឌទម្រង់នៃការរៀបអាពាហ៍ពិពាហ៍នៃព្រះរាជាណាចក្រកម្ពុជា។ នៅក្នុងការប្រៀបធៀបអំពីលក្ខខណ្ឌរវាងការរៀបអាពាហ៍ពិពាហ៍ពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរ និងការរៀបអាពាហ៍ពិពាហ៍ពលរដ្ឋខ្មែរ ជាមួយនឹងជនបរទេសនៅកម្ពុជា បានបង្ហាញឱ្យឃើញពីភាពខុសគ្នាមួយចំនួន។ ការរៀបអាពាហ៍ពិពាហ៍ពលរដ្ឋខ្មែរ ជាមួយនឹងជនបរទេស មានលក្ខណៈខុសពីការរៀបអាពាហ៍ពិពាហ៍ពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរបន្តិចបន្តួច។

ទោះជាយ៉ាងណាក៏ដោយ ក្រៅពីលក្ខខណ្ឌដែលបានកំណត់នេះហើយ នៅមានលក្ខខណ្ឌពិសេសបន្ថែមទៀតចំពោះជនបរទេសដែលចង់រៀបអាពាហ៍ពិពាហ៍ជាមួយពលរដ្ឋខ្មែរ។ យោងតាមកំណត់ទូតរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ចុះថ្ងៃទី៧ ខែមីនា ឆ្នាំ២០១១ បានផ្ញើរទៅគ្រប់ស្ថានទូត និងស្ថានកុងស៊ុលនានាប្រចាំនៅកម្ពុជា ដោយក្នុងនោះបានកំណត់នូវខ្លឹមសារថា បុរសជាជនបរទេសណាម្នាក់ដែលមានបំណងចង់រៀបអាពាហ៍ពិពាហ៍ជាមួយនឹងនារីខ្មែរ ត្រូវមានអាយុមិនលើសពី ៥០ ឆ្នាំ។

**១.២.១.២. ភេទ**

នៅក្នុងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ពុំបានកំណត់អំពីការរៀបអាពាហ៍ពិពាហ៍រវាងភេទដូចគ្នានោះទេ។ ប៉ុន្តែ ប្រសិនបើយើងក្រឡេកទៅមើលរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៤៥ កថាខណ្ឌទី៣ បានចែងថា បុរស និងស្ត្រី មិនសិទ្ធិស្មើគ្នាក្នុងគ្រប់វិស័យទាំងអស់ ជាពិសេសក្នុងអាពាហ៍ពិពាហ៍ និងគ្រួសារ។ នៅក្នុងមាត្រាខាងលើនេះ បានសង្កត់ធ្ងន់ទៅលើពាក្យ បុរស និងស្ត្រី ក្នុងវិស័យអាពាហ៍ពិពាហ៍។ លើសពីនេះទៅទៀតនៅក្នុងមាត្រា ៩៤៨ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាដែលបានចែងពាក់ព័ន្ធអំពីនីតិភាពដែលអាចរៀបអាពាហ៍ពិពាហ៍បានរវាងភាគីដែលជាបុរស និងស្ត្រី។ ដោយផ្អែកលើមាត្រាទាំងពីរខាងលើនេះ បានបង្ហាញថាអាពាហ៍ពិពាហ៍នៅប្រទេសកម្ពុជា អាចកើតឡើង និងមានអានុភាពតាមច្បាប់បានលុះត្រាតែអាពាហ៍ពិពាហ៍នោះ ប្រារព្ធឡើងរវាងបុរស និងស្ត្រីតែប៉ុណ្ណោះ។

**១.២.១.៣. ការព្រមព្រៀង**

ជាគោលការណ៍ ការព្រមព្រៀងអាពាហ៍ពិពាហ៍ ត្រូវតែជាការព្រមព្រៀងដោយសេរី ពោលគឺមិនត្រូវមានការបង្ខំ ឬការបំភ័ន្តច្រឡំលើមនុស្ស ការគម្រាម និងការឆបោកឡើយ។

- ការបង្ខំ និងការភ័ន្តច្រឡំលើមនុស្ស៖ សំដៅលើករណីនៃការភ័ន្តច្រឡំលើអត្តសញ្ញាណមនុស្ស ត្រូវបានចាត់ទុកថាជាមូលហេតុនៃមោឃៈភាពអាពាហ៍ពិពាហ៍ [5]។
- ការគម្រាម ៖ គឺជាមធ្យោបាយខុសច្បាប់ តាមរយៈការជូនដំណឹងពីភាពអាក្រក់ទៅភាគីម្ខាងទៀត ក្នុងគោលដៅឱ្យជននោះមានការភ័យខ្លាច ហើយយល់ព្រមរៀបអាពាហ៍ពិពាហ៍។
- ការឆបោក៖ ជាការបោកប្រាស់ឱ្យជនណាម្នាក់ធ្លាក់ទៅក្នុងការភ័ន្តច្រឡំ ហើយយល់ព្រមរៀបការ ហើយជាមូលហេតុនៃការលុបចោលអាពាហ៍ពិពាហ៍ [6]។

យ៉ាងណាមិញ ក្រមរដ្ឋប្បវេណីមិនបានផ្តល់និយមន័យឱ្យបានច្បាស់លាស់នៃពាក្យ (ការបង្ខំ ការភ័ន្តច្រឡំលើមនុស្ស ការគម្រាម និងការឆបោក) ឡើយ។ ប៉ុន្តែ គេអាចកំណត់បានថា ការបង្ខំ គឺចង់សំដៅលើករណីនៃជនដែលត្រូវរៀបអាពាហ៍ពិពាហ៍ ដោយគ្មានសេរីភាពក្នុងការជ្រើសរើសទាល់តែសោះពោលគឺការបង្ខំបានធ្វើឱ្យសាមីខ្លួនគ្មានឆន្ទៈ នឹងរៀបអាពាហ៍ពិពាហ៍ តែម្តង។ ទន្ទឹមនឹងនេះ បើតាមខ្លឹមសារនៃក្រមរដ្ឋប្បវេណី ការបង្ខំមាន លក្ខណៈខ្លាំងក្លាជាងការគម្រាម មានន័យថា ការបង្ខំគឺមានលក្ខណៈដាច់ណាត់ជាងការគម្រាម នៅត្រង់ថា ការបង្ខំធ្វើឱ្យសាមីខ្លួនគ្មានឆន្ទៈក្នុងការជ្រើសរើស ក៏ប៉ុន្តែសម្រាប់ការគម្រាមកំហែងវិញ សាមីខ្លួនជ្រើសរើសរៀបអាពាហ៍ពិពាហ៍ ក៏ព្រោះតែការភ័យខ្លាច។

### ១.២.១.៤. សមត្ថភាព

ទោះជាក្នុងករណីណាក៏ដោយ ភាគីនៃអាពាហ៍ពិពាហ៍ ត្រូវតែជាមនុស្សមានសមត្ថភាពបង្ហាញឆន្ទៈ។ ក៏ប៉ុន្តែ ជននៅក្រោមអាណាព្យាបាលទូទៅ (ជនដែលស្ថិតនៅក្នុងស្ថានភាពជានិរន្តរ៍ ដែលខ្វះសមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមច្បាប់នៃសកម្មភាពរបស់ខ្លួនដោយ សារមានវិបត្តិផ្នែកបញ្ញាស្មារតី ដូចជាជនវិកលចរិត ជាដើម) គឺអាចរៀបអាពាហ៍ពិពាហ៍បាន នៅក្នុងករណីដែលជននោះអាចមានសមត្ថភាពឆន្ទៈ ក្នុងកម្រិតអប្បបរមាដែលចាំបាច់ ដើម្បីរៀបអាពាហ៍ពិពាហ៍[7]។ ក្នុងករណីបែបនេះ ក្រមរដ្ឋប្បវេណីបានបញ្ញត្តយ៉ាងច្បាស់ថា មិនចាំបាច់តម្រូវឱ្យមានការយល់ព្រមពីអាណាព្យាបាលទូទៅឡើយ។

ឧទាហរណ៍ (១)៖ លោក (ក) មានអាយុ ២៨ឆ្នាំ និងកញ្ញា (ខ) មានអាយុ ២២ឆ្នាំ មានគម្រោងរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា។ ក៏ប៉ុន្តែ ជាអកុសល មិនទាន់បានរៀបអាពាហ៍ពិពាហ៍ផង លោក (ក) ក៏ជួបប្រទះនឹងគ្រោះថ្នាក់ចរាចរណ៍បណ្តាលឱ្យមានការប៉ះទង្គិចដល់បញ្ញាស្មារតីដែលមិនអាចដឹងខុសត្រូវ។ ហេតុដូច្នេះហើយ ទើបមានការប្រកាសដាក់លោក (ក) ឱ្យស្ថិតនៅក្រោមអាណាព្យាបាលទូទៅតាមដីកាសម្រេចរបស់តុលាការ

[5] ក្រមរដ្ឋប្បវេណី, ៨ ធ្នូ ២០០៧, មាត្រា ៩៥៨

[6] ក្រមរដ្ឋប្បវេណី, ៨ ធ្នូ ២០០៧, មាត្រា ៩៦៣

[7] ក្រមរដ្ឋប្បវេណី, ៨ ធ្នូ ២០០៧, មាត្រា ៩៥៤

ដោយកំណត់ឱ្យបងប្រុសបង្កើតរបស់លោក (ក) ធ្វើជាអាណាព្យាបាល។ ក្រោយមក ស្ថានភាពរបស់ លោក (ក) ក៏បានល្អប្រសើរវិញបន្តិចម្តងៗ ក៏ប៉ុន្តែមិនទាន់បានជាសះស្បើយទាំងស្រុងនៅឡើយ។ ក្នុងករណីដែលលោក (ក) អាចបង្ហាញឆន្ទៈថានឹងរៀបការជាមួយកញ្ញា (ខ) បាននៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន (មេឃុំ ឬចៅសង្កាត់) នោះលោក (ក) និងកញ្ញា (ខ) អាចរៀបការជាមួយគ្នាបាន ដោយមិនចាំបាច់មានការយល់ព្រមឯកភាពពីបងប្រុសបង្កើតរបស់លោក (ក) នោះទេ។

ចំពោះជនដែលស្ថិតនៅក្រោមហិតូបត្ថម្ភ (ជនដែលមានសមត្ថភាពតិចតួចបំផុតក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី) អាចរៀបអាពាហ៍ពិពាហ៍បាន ដោយមិនចាំបាច់មានការយល់ព្រមពីហិតូបត្ថម្ភកៈ ឡើយ។

ឧទាហរណ៍ (២)៖ លោក (ក) មានអាយុ ៣០ឆ្នាំ។ ក្រោយពីជួបប្រទះនូវគ្រោះថ្នាក់ចរាចរណ៍ដែលមានការប៉ះទង្គិចត្រង់ក្បាលរួចមក លោក (ក) បានក្លាយជាមនុស្សដែលមិនសូវដឹងខុសត្រូវដូចពីមុន ប៉ុន្តែវេជ្ជបណ្ឌិតជំនាញបានបញ្ជាក់ថា គាត់មិនមែនដឹងខុសត្រូវទាំងស្រុងទេ គឺគ្រាន់តែដឹងខុសត្រូវបន្តិចបន្តួចប៉ុណ្ណោះ។ ក្នុងករណីបែបនេះ គឺគេអាចស្នើសុំឱ្យតុលាការសម្រេចដាក់ លោក (ក) ស្ថិតក្រោមហិតូបត្ថម្ភតាម ដីកាសម្រេច ដោយជ្រើសតាំងនរណាម្នាក់ឱ្យធ្វើជាហិតូបត្ថម្ភកៈ (អ្នកគ្រប់គ្រង) របស់លោក (ក)។ ទោះបីជាក្នុងយ៉ាងនេះក៏ដោយ លោក (ក) នៅតែអាចរៀបការបាន ដោយមិនចាំបាច់យល់ព្រមពីហិតូបត្ថម្ភកៈឡើយ។

### ១.២.១.៥. ឯកពន្ធភាព

ផ្អែកតាមមាត្រា ៩៤៨ នៃក្រមរដ្ឋប្បវេណីបានចែងថា៖ បុគ្គលដែលមានសហព័ទ្ធហើយ ពុំអាចរៀបអាពាហ៍ពិពាហ៍ទៀតបានឡើយ។ ម្យ៉ាងទៀត ការបំពានលក្ខខណ្ឌនេះ គឺជាបទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាម មាត្រា ៤ និងមាត្រា ៩ នៃច្បាប់ស្តីពីឯកពន្ធភាព (ទោសដាក់ពន្ធនាគារពី ៦ខែ ទៅ ១ឆ្នាំ និង/ឬពិន័យជាប្រាក់ ២សែនរៀល ទៅ១លានរៀល។ ដូចគ្នានេះដែរ យោងតាមមាត្រា ៣៥០ នៃក្រមព្រហ្មទណ្ឌ (បទទ្វេពន្ធភាព) កំណត់នូវទោសដាក់ពន្ធនាគារពី ១ ខែ ទៅ ១ ឆ្នាំ និងពិន័យជាប្រាក់ពី ១ សែនរៀល ទៅ ២ លានរៀល ចំពោះអំពើដែលចុះបញ្ជីអាពាហ៍ពិពាហ៍ថ្មី មុនការរំលាយចំណងអាពាហ៍ពិពាហ៍ចាស់។

### ១.២.១.៦ ប្រាក់ចំណូលរបស់ជនបរទេស

យោងតាមកំណត់ទូតរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ចុះថ្ងៃទី៧ ខែមីនា ឆ្នាំ ២០១១ បានផ្ញើរទៅគ្រប់ស្ថានទូត និងស្ថានកុងស៊ុលនានាប្រចាំនៅកម្ពុជា ដោយក្នុងនោះបានកំណត់នូវខ្លឹមសារផងដែរថា បុរសជាជនបរទេសណាម្នាក់ដែលមានបំណងចង់រៀបអាពាហ៍ពិពាហ៍ជាមួយនឹងនារីខ្មែរ ត្រូវមានប្រាក់ចំណូលជាមធ្យមយ៉ាងតិច ២៥០០ ដុល្លារក្នុងមួយខែ ទើបអាចពិចារណាឱ្យរៀបអាពាហ៍ពិពាហ៍ជាមួយនារីខ្មែរបាន។

ការកំណត់បែបនេះ មានគោលបំណងក្នុងការការពារស្ត្រីខ្មែរគ្រប់រូប ដើម្បីជួយដល់ស្ត្រីខ្មែរទូទៅកុំឱ្យមានការកេងប្រវ័ញ្ចផ្លូវភេទ និងការជួញដូរពលកម្មហើយនោះ។ ការកំណត់បែបនេះក៏បានបង្ហាញមន្ថែមទៀតថាប្រាក់ចំណូលរបស់បុរសបរទេសដែលចង់បានភរិយាជាស្ត្រីខ្មែរ នឹងអាចជួយឱ្យនារីខ្មែរដែលមានស្វាមីជាជនបរទេស នឹងទទួលបានជីវភាពរស់នៅមួយយ៉ាងសមរម្យបន្ទាប់ពីរៀបការរួច។

### ១.២.២. លក្ខខណ្ឌទម្រង់នៃការរៀបអាពាហ៍ពិពាហ៍

លក្ខខណ្ឌទម្រង់នៃការរៀបអាពាហ៍ពិពាហ៍ គឺជាលក្ខខណ្ឌដ៏សំខាន់មួយទៀតដើម្បីឱ្យអាពាហ៍ពិពាហ៍មួយក្លាយទៅជាអាពាហ៍ពិពាហ៍ដែលស្របច្បាប់ និងបង្កើតឱ្យមាននូវសិទ្ធិ និងករណីយកិច្ចរវាងសហព័ទ្ធតាមផ្លូវច្បាប់។ ហេតុនេះហើយ បុគ្គលដែលមានបំណងរៀបអាពាហ៍ពិពាហ៍ ក្រៅពីត្រូវមានលក្ខណៈសម្បត្តិត្រឹមត្រូវតាមលក្ខខណ្ឌគ្រឹះហើយនោះ ក៏ត្រូវបំពេញនូវលក្ខខណ្ឌទម្រង់បន្ថែមទៀតផងដែរ។

លក្ខខណ្ឌទម្រង់នៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស មានភាពខុសប្លែកពីលក្ខខណ្ឌទម្រង់នៃអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរ ត្រង់នីតិវិធីបន្តិចបន្តួច ដោយនីតិវិធីនោះត្រូវបានកំណត់ដោយអនុក្រឹត្យលេខ១៨៣ អនក្រ.បក ចុះថ្ងៃទី៣ វិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស។

#### ១.២.២.១. ការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍

អាពាហ៍ពិពាហ៍មួយនឹងមានអានុភាពកើតឡើង ដោយការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការជូនដំណឹងជាសាធារណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និងការចុះបញ្ជីនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន[8]។ ការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការជូនដំណឹងជាសាធារណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និងការចុះបញ្ជីអាពាហ៍ពិពាហ៍ដែលបានកំណត់នៅក្នុងខាងលើនេះ ត្រូវធ្វើឡើងដោយផ្អែកតាមនីតិវិធីដែលបានកំណត់នៅក្នុងបទប្បញ្ញត្តិស្តីពីការចុះបញ្ជីអត្រានុកូលដ្ឋាន។

យ៉ាងណាមិញ ចំពោះពាក្យសុំរៀបអាពាហ៍ពិពាហ៍ពុំអាចទទួលយកបានឡើយ បើបានទទួលស្គាល់ថាអាពាហ៍ពិពាហ៍នោះ ផ្ទុយនឹងបញ្ញត្តិដែលចាប់ពីមាត្រា៩៤៨ (អាយុគ្រប់លក្ខណៈរៀបអាពាហ៍ពិពាហ៍) រហូតដល់មាត្រា៩៥៤ (ការរៀបអាពាហ៍ពិពាហ៍របស់ជននៅក្រោមអាណាព្យាបាលទូទៅ) ខាងលើនេះ ឬបទដ្ឋានគតិយុត្តផ្សេងទៀត។

[8] ក្រមរដ្ឋប្បវេណី, ៨ ធ្នូ ២០០៧, មាត្រា ៩៥៥

### ១.២.២.២. នីតិវិធី និងបែបបទក្នុងការរៀបអាពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេសនៅក្នុងប្រទេសកម្ពុជា

#### ១.២.២.២.១. ដំណាក់កាលរដ្ឋបាល

យោងតាម អនុក្រឹត្យស្ដីពីការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស សាមីខ្លួនដែលជាជនបរទេស ត្រូវតែដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ដោយភ្ជាប់ជាមួយនូវឯកសារដូចជា[9]៖

- ពាក្យសុំរៀបអាពាហ៍ពិពាហ៍
- ឯកសារថតចម្លងនៃលិខិតឆ្លងដែនរបស់សាមីខ្លួនជនបរទេសមានទិដ្ឋាការចូលប្រទេសកម្ពុជា ដែលមានសុពលភាព
- លិខិតបញ្ជាក់ភាពនៅលីវ ឬពោះមាយ ឬមេមាយ ចេញដោយសមត្ថកិច្ចនៃប្រទេសរបស់សាមីខ្លួនជនបរទេស
- លិខិតបញ្ជាក់សុខភាពចេញដោយសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា
- លិខិតថ្កោលទោសចេញដោយសមត្ថកិច្ចនៃប្រទេសរបស់សាមីខ្លួនជនបរទេស
- លិខិតបញ្ជាក់អំពីមុខរបរពិតប្រាកដរបស់សាមីខ្លួនជនបរទេស ដែលធានាដល់ជីវភាពរស់នៅ ចេញដោយសមត្ថកិច្ចនៃប្រទេសរបស់សាមីខ្លួនជនបរទេស។

ឯកសារខាងលើ ចាប់ផ្ដើមជាដំបូងដោយត្រូវដាក់ទៅស្ថានទូត ឬស្ថានដំណាងនៃប្រទេសនោះប្រចាំនៅកម្ពុជា ដើម្បីឱ្យមានការបញ្ជាក់ពីនីត្យានុកូលភាពនៃឯកសារទាំងអស់នោះ។ លើសពីនេះ ដំណើរនៃនីតិវិធីជាបន្តបន្ទាប់៖ គឺស្ថានទូត ឬស្ថានដំណាងនៃប្រទេសនោះដែលប្រចាំនៅកម្ពុជា ត្រូវបញ្ជូលរាល់សំណុំឯកសារពាក់ព័ន្ធទាំងអស់ ទៅឱ្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃប្រទេសកម្ពុជា។ បន្ទាប់មក ក្រសួងការបរទេស ពិនិត្យ និងផ្ដល់យោបល់លើសំណុំឯកសារ ហើយជូនដំណឹងទៅសាមីជនបរទេស ក្នុងរយៈពេលយ៉ាងយូរ ០៥ ថ្ងៃការងារ ព្រមទាំងជូនដំណឹងទៅស្ថានទូត ឬស្ថានតំណាងវិញផងដែរ។ រួចមកក្រសួងការបរទេសបញ្ជូនសំណុំឯកសារទៅក្រសួងមហាផ្ទៃវិញ។ ក្រសួងមហាផ្ទៃ ត្រូវចុះបញ្ជីសំណុំឯកសារ និងជូនដំណឹងទៅសាមីខ្លួនជនបរទេស ក្នុងរយៈពេល ០៥ ថ្ងៃការងារ។ ក្រសួងមហាផ្ទៃជូនដំណឹងពីការសុំរៀបអាពាហ៍ពិពាហ៍ ទៅមន្ត្រីអត្រានុកូលដ្ឋាននៃ ឃុំសង្កាត់ នៃលំនៅដ្ឋានរបស់សាមីខ្លួនពលរដ្ឋខ្មែរ[10]។

[9] អនុក្រឹត្យស្ដីពីការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស, ២៣ វិច្ឆិកា ២០០៨, មាត្រា ៦

[10] អនុក្រឹត្យស្ដីពីការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស, ២៣ វិច្ឆិកា ២០០៨, មាត្រា ៨

### ១.២.២.២.២. ដំណាក់កាលនៃការចុះបញ្ជីអាពាហ៍ពិពាហ៍

យោងតាមអនុក្រឹត្យស្តីពីការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស សាមីខ្លួនជនបរទេសត្រូវដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ទៅមន្ត្រីអត្រានុកូលដ្ឋាននៃឃុំសង្កាត់ នៃលំនៅឋានរបស់សាមីខ្លួនពលរដ្ឋខ្មែរ។ ស្របពេលជាមួយគ្នានេះ សាមីខ្លួនពលរដ្ឋខ្មែរក៏ដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ទៅមន្ត្រីអត្រានុកូលដ្ឋាននៃឃុំសង្កាត់ខាងលំនៅឋានរបស់ខ្លួនដែរ ដោយភ្ជាប់ជាមួយនូវឯកសារផ្សេងៗដែលមានរៀបរាប់នៅក្នុង កថាខណ្ឌទី ២ មាត្រា៩ នៃអនុក្រឹត្យខាងលើ។ មន្ត្រីអត្រានុកូលដ្ឋាន នៃឃុំសង្កាត់ខាងលំនៅឋានរបស់សាមីខ្លួនទាំងពីរនាក់ក្នុងរយៈពេល ០៣ ថ្ងៃការងារ។ បន្ទាប់មក បើពិនិត្យឃើញថាត្រឹមត្រូវហើយ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវចេញប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ចំនួន ០៥ ច្បាប់ ដោយមានបិទរូបថត របស់សាមីខ្លួនទាំងពីរនាក់នៅផ្នែកខាងលើគៀនជ្រុងខាងស្តាំ ដោយប័ណ្ណមួយ ត្រូវរក្សាទុកនៅសាលាឃុំសង្កាត់ និងប័ណ្ណដែលនៅសល់ ត្រូវបិទផ្សាយក្នុងរយៈពេល ១០ ថ្ងៃ។ ចំពោះការបិទផ្សាយ មាននៅ ០៤ កន្លែងដូចជា៖[11]

- ស្ថានទូត ឬស្ថានតំណាងនៃប្រទេសសាមីខ្លួន ជនបរទេសប្រចាំនៅព្រះរាជាណាចក្រកម្ពុជា
- លំនៅឋានអចិន្ត្រៃយ៍របស់សាមីខ្លួនពលរដ្ឋខ្មែរ
- សាលាឃុំសង្កាត់ នៃលំនៅឋានអចិន្ត្រៃយ៍របស់សាមីខ្លួនពលរដ្ឋខ្មែរ
- លំនៅឋាន ឬទីកន្លែងស្នាក់នៅរបស់សាមីខ្លួនជនបរទេស ប្រសិនបើមាន។

ការបិទផ្សាយនេះ ក្នុងគោលបំណងផ្សព្វផ្សាយ និងទុករយៈពេល ១០ ថ្ងៃទុកសម្រាប់ឱ្យមានការប្តឹងជំទាស់ ដូចករណីនៃនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរដែរ។ នីតិវិធីជាបន្តទៀត គឺដូចជានីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរដែរ។ បន្ទាប់ពីបានចុះបញ្ជីអាពាហ៍ពិពាហ៍រួចហើយ មន្ត្រីអត្រានុកូលដ្ឋានត្រូវធ្វើរបាយការណ៍ជាបន្ទាន់ផ្ញើមកក្រសួង តាមរយៈក្រុង ស្រុក ខណ្ឌ រាជធានីភ្នំពេញ យោងតាមសេចក្តីណែនាំលេខ ០០១ សណន ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០០៩ របស់ក្រសួងមហាផ្ទៃ ស្តីពីការអនុវត្តអនុក្រឹត្យស្តីពីការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស មាត្រា ១០។

### ១.២.២.២.៣. ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍

អាពាហ៍ពិពាហ៍នឹងចាត់ទុកថាត្រឹមត្រូវតាមលក្ខណៈច្បាប់បាន លុះត្រាតែបុរស និងនារី ដែលស្ម័គ្រចិត្តយកគ្នាជាប្តី ប្រពន្ធ ចុះកិច្ចសន្យាអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានខាងលំនៅរបស់នារី។ កិច្ច

[11] អនុក្រឹត្យស្តីពីការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស, ២៣ វិច្ឆិកា ២០០៨, មាត្រា ១០

សន្យានេះត្រូវចុះក្នុងបញ្ជីអាពាហ៍ពិពាហ៍ ហើយត្រូវចុះហត្ថលេខាដោយមន្ត្រីអត្រានុកូលដ្ឋាន ប្តី ប្រពន្ធ និង សាក្សីគ្រប់អាយុផងដែរ។

## **១.៣. មោឃៈភាពនៃអាពាហ៍ពិពាហ៍**

មោឃៈភាពនៃអាពាហ៍ពិពាហ៍ គឺជាអាពាហ៍ពិពាហ៍មួយដែលពុំអាចកើតឡើងបានតាំងពីដំបូងដោយសារតែភាពផ្ទុយច្បាប់មានកម្រិតខ្ពស់ ដែលញ៉ាំងឱ្យអាពាហ៍ពិពាហ៍នោះពុំមានអានុភាព។

### **១.៣.១. ករណីដែលចាត់ទុកជាមោឃៈ**

អាពាហ៍ពិពាហ៍មួយនឹងត្រូវចាត់ទុកជាមោឃៈ ប្រសិនបើអាពាហ៍ពិពាហ៍នោះបានប្រព្រឹត្តឡើងដោយពុំបានបំពេញតាមលក្ខខណ្ឌដែលត្រូវបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណី។ ភាពផ្ទុយនឹងច្បាប់ដែលនាំឱ្យមោឃៈភាពអាពាហ៍ពិពាហ៍កើតមានឡើងមាន[12]៖

#### **១.៣.១.១. មោឃៈភាពអាពាហ៍ពិពាហ៍ដែលគ្មានឆន្ទៈរៀបអាពាហ៍ពិពាហ៍**

អាពាហ៍ពិពាហ៍ត្រូវចាត់ទុកជាមោឃៈ កាលណាសហព័ទ្ធណាម្នាក់ប្តឹងថាខ្លួនត្រូវបានគេចាប់បង្ខំឱ្យរៀបអាពាហ៍ពិពាហ៍[13]។ រាល់ការរៀបអាពាហ៍ពិពាហ៍ទាំងឡាយណាដែលពុំមានការព្រមព្រៀងគ្នាត្រូវបានចាត់ទុកថាគ្មានឆន្ទៈរៀបអាពាហ៍ពិពាហ៍។ ភាពគ្មានឆន្ទៈរៀបអាពាហ៍ពិពាហ៍រួមបញ្ចូលទាំង ការភាន់ច្រឡំលើមនុស្ស ការបង្ខំ និងមូលហេតុផ្សេងៗទៀត។ ការភាន់ច្រឡំទៅលើមនុស្សអាចជាការភាន់ច្រឡំដោយសាររូបរាងរបស់បុគ្គលនោះ (កូនភ្លោះ) ឬភាន់ច្រឡំទៅលើឋានៈរបស់បុគ្គលជាដើម។ ក្រៅពីនេះមូលហេតុផ្សេងៗទៀតដូចជាការរៀបអាពាហ៍ពិពាហ៍ក្នុងហេតុផល ឬដើម្បីទទួលបានផលប្រយោជន៍អ្វីមួយក៏ត្រូវចាត់ទុកថាជាមោឃៈភាពនៃអាពាហ៍ពិពាហ៍ផងដែរ។

#### **១.៣.១.២. មោឃៈភាពអាពាហ៍ពិពាហ៍ដែលពុំបានបំពេញនូវលក្ខខណ្ឌទម្រង់**

ប្រសិនបើភាគីមិនបាន ដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការជូនដំណឹងជាសាធារណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ ឬមិនបានចុះបញ្ជីអាពាហ៍ពិពាហ៍នោះទេ អាពាហ៍ពិពាហ៍នោះក៏នឹងត្រូវចាត់ទុកជាមោឃៈផងដែរ[14]។ ក្នុងចំណុចនេះដែរ ប្រសិនបើភាគីបានបំពេញនូវលក្ខខណ្ឌទម្រង់ដែលបានរៀបរាប់ខាងលើ ប៉ុន្តែមានវិការៈបន្តិចបន្តួចទៅលើនីតិវិធីនោះមិនអាចជាហេតុដែលនាំឱ្យមានមោឃៈភាពនៃអាពាហ៍ពិពាហ៍ឡើយ។

[12] ក្រមរដ្ឋប្បវេណី, ៨ ធ្នូ ២០០៧, មាត្រា ៩៥៨

[13] ក្រមរដ្ឋប្បវេណី, ៨ ធ្នូ ២០០៧, មាត្រា ៩៥៨ ចំណុច ក

[14] ក្រមរដ្ឋប្បវេណី, ៨ ធ្នូ ២០០៧, មាត្រា ៩៥៨ ចំណុច ខ

### ១.៣.២. អានុភាពនៃមោឃៈភាពអាពាហ៍ពិពាហ៍

ក្នុងពេលដែលអាពាហ៍ពិពាហ៍ត្រូវបានមោឃៈភាព នោះមានន័យថាអាពាហ៍ពិពាហ៍មិនបានកើតឡើងទេ គឺវាមិនមានអានុភាពតាំងពីដំបូង។ ហេតុដូចនោះហើយ ទំនាក់ទំនងរវាងប្ដីប្រពន្ធ និងកូនតាមផ្លូវច្បាប់ពុំត្រូវបានយកមកអនុវត្តឡើយ។ ក្នុងចំណុចនេះ ដោយសារតែអាពាហ៍ពិពាហ៍ពុំមានអានុភាពតាំងពីដំបូង ហេតុដូចនេះហើយទើបនាំទំនាក់ទំនងញាតិរវាងប្ដីប្រពន្ធដែលមិនមែនជាសហព័ទ្ធ ក៏ពុំបានកើតមានឡើងផងដែរចំណែកឯ ទំនាក់ទំនងចំពោះកូនវិញ ក៏ពុំអាចសន្មតអំពីបិតុភាពនៃកូននោះបានដែរ។ ត្បិតតែមោឃៈភាពនៃអាពាហ៍ពិពាហ៍ពុំអាចសន្មតបិតុភាពបានក៏ពិតមែន ប៉ុន្តែ គេអាចសន្មតអំពីមាតុភាពបាន។ ចំពោះទ្រព្យសម្បត្តិដែលភាគីមានកំឡុងពេលមោឃៈភាពត្រូវបានគេពិចារណាដូចទៅនឹងការលែងលះដែរ។

### ១.៣.៣. ការដាក់បណ្ដឹងទាមទារឱ្យបញ្ជាក់មោឃៈភាពអាពាហ៍ពិពាហ៍

ជាទូទៅការដាក់ពាក្យបណ្ដឹងបញ្ជាក់ទៅតុលាការ មិនមែនជាការសុំទាមទារទៅតុលាការឱ្យធ្វើមោឃៈភាពអាពាហ៍ពិពាហ៍ឡើយ។ ដោយសារតែមោឃៈភាពអាពាហ៍ពិពាហ៍ធ្វើឱ្យអាពាហ៍ពិពាហ៍នោះ ពុំបានកើតឡើងតាំងពីដំបូង ដូចនេះការដាក់បណ្ដឹងនោះ គឺជាការដាក់បណ្ដឹងទាមទារឱ្យតុលាការបញ្ជាក់អំពីមោឃៈភាពអាពាហ៍ពិពាហ៍តែប៉ុណ្ណោះ[15]។ បណ្ដឹងទាមទារឱ្យបញ្ជាក់មោឃៈភាពអាពាហ៍ពិពាហ៍ត្រូវធ្វើឡើងដោយផ្អែកតាមច្បាប់ស្ដីពីនីតិវិធីបណ្ដឹងឋានៈបុគ្គល[16] និងនីតិវិធីពាក់ព័ន្ធ ត្រូវអនុលោមតាមក្រមនីតិវិធីរដ្ឋប្បវេណី។ នៅក្នុងក្រមរដ្ឋប្បវេណីពុំបានធ្វើការកម្រិតអំពីជនដែលអាចប្ដឹងបានទេ ដូចនេះ គ្រប់ជនដែលមានផលប្រយោជន៍ពាក់ព័ន្ធទាំងអស់ អាចដាក់បណ្ដឹងទាមទារឱ្យបញ្ជាក់មោឃៈភាពអាពាហ៍ពិពាហ៍បានដោយពុំមានការកម្រិតអំឡុងពេលនៃអាជ្ញាយុកាលឡើយ។ ម្យ៉ាងវិញទៀត ច្បាប់បានកំណត់យកសាលាដំបូងនៃលំនៅដ្ឋានរបស់ភាគីដែលពាក់ព័ន្ធនឹងបណ្ដឹង ជាតុលាការមានសមត្ថកិច្ចលើបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល[17]។

## ១.៤. ការលុបចោលអាពាហ៍ពិពាហ៍

ការលុបចោលអាពាហ៍ពិពាហ៍ គឺជាការបញ្ចប់ពាហ៍ពិពាហ៍ដោយ អាចលុបចោលបាននៅក្នុងករណីដែល អាពាហ៍ពិពាហ៍នោះ មានលក្ខណៈផ្ទុយនឹងបញ្ញត្តិច្បាប់ ទោះបីជាអាពាហ៍ពិពាហ៍នោះកើតឡើងដោយភាគីដែលមានឆន្ទៈរៀបអាពាហ៍ពិពាហ៍ក៏ដោយ។ ភាពផ្ទុយច្បាប់នៃការលុបចោលអាពាហ៍ពិពាហ៍ មានលក្ខណៈទាបជាងករណីនៃមោឃៈភាពអាពាហ៍ពិពាហ៍ដែលជាហេតុដែលនាំឱ្យអាពាហ៍ពិពាហ៍មានអានុភាពរហូតដល់ពេលលុបចោល។

---

[15] នីតិព្រហ្មទណ្ឌ និងនីតិគ្រួសារ ដោយសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងចាំង ស៊ុណាត, ឆ្នាំ ២០១៧, ទំព័រ ៣៣៤

[16] ច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល, មាត្រា ៣

[17] ច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល, មាត្រា ៥

### ១.៤.១. ករណីនៃការលុបចោលអាពាហ៍ពិពាហ៍

យោងតាមក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ បានកំណត់អំពីមូលហេតុដែលនាំឱ្យអាពាហ៍ពិពាហ៍នឹងត្រូវបានលុបចោលដោយសារករណីមួយចំនួន។ យើងសង្កេតឃើញថា នៅក្នុងក្រមរដ្ឋប្បវេណី បានបង្ហាញនូវមូលហេតុដែលនាំឱ្យអាពាហ៍ពិពាហ៍ត្រូវបានលុបចោល ហើយមានលក្ខណៈជាពីរសណ្ឋានគឺ ការលុបចោលអាពាហ៍ពិពាហ៍ដែលមិនត្រឹមត្រូវតាមច្បាប់ និងការលុបចោលអាពាហ៍ពិពាហ៍ដោយការគម្រាម ឬឆបោក[18]។

#### ១.៤.១.១. ការលុបចោលអាពាហ៍ពិពាហ៍ដែលមិនត្រឹមត្រូវតាមច្បាប់

ការលុបចោលអាពាហ៍ពិពាហ៍ដែលមិនត្រឹមត្រូវតាមច្បាប់ គឺជាអាពាហ៍ពិពាហ៍ដែលផ្ទុយនឹងបញ្ញត្តិច្បាប់ដែលមានចែងក្នុងក្រមរដ្ឋប្បវេណី[19]។

**ក. អាយុ** ៖ បុរស និងនារីដែលមិនទាន់ដល់នីតិភាព មិនអាចរៀបអាពាហ៍ពិពាហ៍បានឡើយ[20]។ នីតិភាពនៃការរៀបអាពាហ៍ពិពាហ៍គឺបុរសត្រូវមានអាយុចាប់ពី ១៨ ឆ្នាំឡើងទៅ ចំពោះនារីត្រូវមានអាយុចាប់ពី ១៦ ឆ្នាំឡើងទៅ។

**ខ. ការហាមឃាត់មិនឱ្យមានទ្វេពន្ធភាព** ៖ បុគ្គលដែលមានសហព័ទ្ធរួចហើយ ពុំអាចរៀបអាពាហ៍ពិពាហ៍បានទៀតនោះទេ[21]។ ការរៀបអាពាហ៍ពិពាហ៍ថ្មីមួយ មិនត្រូវកើតមានឡើយប្រសិនបើចំណងអាពាហ៍ពិពាហ៍មុនពុំទាន់បានរំលាយ។ ដូចនេះ ប្រសិនបើសហព័ទ្ធណាម្នាក់មានបំណងចង់រៀបអាពាហ៍ពិពាហ៍ថ្មី ត្រូវរង់ចាំរហូតដល់ចំណងអាពាហ៍ពិពាហ៍មុនរបស់ខ្លួនរលត់ជាមុនសិន ពុំនោះទេអាពាហ៍ពិពាហ៍ថ្មីនឹងត្រូវចាត់ទុកជាមោឃៈ។

**គ. អាពាហ៍ពិពាហ៍រវាងញាតិលោហិត ឬញាតិពន្ធ** ៖ អាពាហ៍ពិពាហ៍នឹងត្រូវបានហាមឃាត់ប្រសិនបើរៀបអាពាហ៍ពិពាហ៍រវាងបុគ្គលដែលជាប់ចំណងញាតិលោហិត ឬរវាងសាខាញាតិក្នុងថ្នាក់ទី៣ ទោះសាខាញាតិនោះមានខាន់ស្លាក្តី ឥតខាន់ស្លាក្តី រួមម្តាយ ឬរួមឪពុក[22]។ លើសពីនេះអាពាហ៍ពិពាហ៍ក៏នឹងត្រូវហាមឃាត់ផងដែរ ចំពោះការរៀបអាពាហ៍ពិពាហ៍រវាងញាតិពន្ធខ្សែផ្ទាល់ និងសាខាញាតិពន្ធក្នុងថ្នាក់ទី៣ រាប់ទាំងថ្នាក់ទី៣ផង[23]។

---

[18] ក្រមរដ្ឋប្បវេណី, ៨ ធ្នូ ២០០៧, មាត្រា ៩៥៩
[19] ក្រមរដ្ឋប្បវេណី, ៨ ធ្នូ ២០០៧, មាត្រា ៩៦០
[20] ក្រមរដ្ឋប្បវេណី, ៨ ធ្នូ ២០០៧, មាត្រា ៩៤៨
[21] ក្រមរដ្ឋប្បវេណី, ៨ ធ្នូ ២០០៧, មាត្រា៩៤៩
[22] ក្រមរដ្ឋប្បវេណី, ៨ ធ្នូ ២០០៧, មាត្រា៩៥១
[23] ក្រមរដ្ឋប្បវេណី, ៨ ធ្នូ ២០០៧, មាត្រា៩៥២

**ឃ. ការហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍ថ្មី** ៖ នារីពុំអាចរៀបអាពាហ៍ពិពាហ៍ថ្មីបានឡើយប្រសិនបើ ១២០ ថ្ងៃបន្ទាប់ពីថ្ងៃដែលអាពាហ៍ពិពាហ៍មុនត្រូវបានរំលត់ ពុំទាន់បានកន្លងផុតទៅ[24]។

### ១.៤.១.២. ការលុបចោលអាពាហ៍ពិពាហ៍ដោយការគម្រាម ឬឆបោក

ជនដែលបានរៀបអាពាហ៍ពិពាហ៍ដោយសារការឆបោក ឬគម្រាម អាចទាមទារទៅតុលាការឱ្យលុបចោលអាពាហ៍ពិពាហ៍នោះបាន[25]។ ជនដែលជាភាគីនៃអាពាហ៍ពិពាហ៍អាចទទួលរងនូវការឆបោក ឬការគម្រាមពីសំណាក់ភាគីនៃអាពាហ៍ពិពាហ៍ម្ខាងទៀត ឬភាគីណាមួយផ្សេងទៀតដើម្បីគោលបំណងអ្វីមួយ ឬផលប្រយោជន៍ណាមួយ។

ទោះជាយ៉ាងណាក៏ដោយ សិទ្ធលុបចោលរបស់ភាគីដែលត្រូវបានគេឆបោក ឬការគម្រាមនឹងត្រូវបានរលត់ប្រសិនបើអំឡុងពេល ០៣ ខែ ដែលគិតចាប់ពីពេលដែលភាគីបានរកឃើញការឆបោក ឬបានរួចខ្លួនពីការគម្រាមបានកន្លងផុតទៅ ឬប្រសិនបើភាគីបានធ្វើសច្ចានុមតិ[26]។

### ១.៤.២. អានុភាពនៃការលុបចោលអាពាហ៍ពិពាហ៍

អានុភាពនៃការលុបចោលអាពាហ៍ពិពាហ៍ ពុំមានអានុភាពទៅលើអតីតកាលទេ ពោលគឺគ្រាន់តែមានអានុភាពរំលាយអាពាហ៍ពិពាហ៍ចំពោះអនាគតប៉ុណ្ណោះ[27]។ ឧទាហរណ៍ ការសន្មតបិតុភាព ចំពោះកូនដែលបានកើតមុនពេលអាពាហ៍ពិពាហ៍ត្រូវបានលុបចោល នោះត្រូវសន្មតថាកូននោះ គឺជាកូនរបស់ប្ដីមុនពេលដែលបានលុបចោលអាពាហ៍ពិពាហ៍។ យោងតាមឧទាហរណ៍ខាងលើនេះមានន័យថា ប្ដីប្រពន្ធមួយគូបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា និងមានកូនជាមួយគ្នាក្នុងចំណងអាពាហ៍ពិពាហ៍នោះ ប៉ុន្តែស្រាប់តែចំណងអាពាហ៍ពិពាហ៍ត្រូវបានលុបចោលដោយសារមូលហេតុណាមួយដែលបានកំណត់នៅក្នុងបញ្ញត្តច្បាប់។ ក្នុងស្ថានភាពបែបនេះ ទោះបីជាអាពាហ៍ពិពាហ៍ត្រូវបានលុបចោលក៏ដោយ ក៏មិនមានន័យថាបុរសដែលជាប្ដីនោះលែងជាឪពុករបស់កូននោះដែរ ពោលគឺបុរសដែលជាប្ដីនោះនៅតែត្រូវបានសន្មតថាជាបិតុភាពរបស់កូននោះ។ ចំណែកឯការបែងចែកទ្រព្យសម្បត្តិក្រោយការលុបចោលអាពាហ៍ពិពាហ៍វិញ ត្រូវយកបញ្ញត្តស្ដីពីការបែងចែកទ្រព្យសម្បត្តិនៅក្រោយពេលលែងលះមកអនុវត្តដូចគ្នាផងដែរ។

---

[24] ក្រមរដ្ឋប្បវេណី, ៨ ធ្នូ ២០០៧, មាត្រា៩៥០

[25] ក្រមរដ្ឋប្បវេណី, ៨ ធ្នូ ២០០៧, មាត្រា៩៦៣ វាក្យខណ្ឌទី១

[26] ក្រមរដ្ឋប្បវេណី, ៨ ធ្នូ ២០០៧, មាត្រា៩៦៣ វាក្យខណ្ឌទី២

[27] ក្រមរដ្ឋប្បវេណី, ៨ ធ្នូ ២០០៧, មាត្រា៩៦៤ វាក្យខណ្ឌទី១

### ១.៤.៣. ការដាក់បណ្ដឹងទាមទារឱ្យលុបចោលអាពាហ៍ពិពាហ៍

បុគ្គលដែលមានបំណងទាមទារឱ្យលុបចោលអាពាហ៍ពិពាហ៍ ត្រូវដាក់ពាក្យបណ្ដឹងទាមទារទៅកាន់តុលាការឱ្យចេញសាលក្រម ឬសាលដីកាស្ថាពរដោយផ្អែកតាមច្បាប់ស្ដីពីនីតិវិធីបណ្ដឹងឋានៈបុគ្គល[28] និងនីតិវិធីពាក់ព័ន្ធ ត្រូវអនុលោមតាមក្រមនីតិវិធីរដ្ឋប្បវេណី។ ការដាក់ពាក្យបណ្ដឹងទៅតុលាការអំពីការលុបចោលអាពាហ៍ពិពាហ៍ គឺជាការដាក់ពាក្យបណ្ដឹងទាមទារឱ្យតុលាការលុបចោលអាពាហ៍ពិពាហ៍នោះ ដែលខុសពីការដាក់ពាក្យបណ្ដឹងទៅតុលាការដើម្បីឱ្យតុលាការបញ្ជាក់អំពីមោឃៈភាពនៃអាពាហ៍ពិពាហ៍។ ការដាក់ពាក្យបណ្ដឹងទាមទារឱ្យតុលាការលុបចោលអាពាហ៍ពិពាហ៍ គឺជាបណ្ដឹងដែលទាមទារឱ្យតុលាការចេញសាលក្រមទៅលើការប្រកាសបង្កើតជាថ្មីនូវទំនាក់ទំនងគតិយុត្តដែលមានកំណត់ក្នុងច្បាប់សារជាតុ ហើយវានឹងពុំមានអានុភាពទេ បើពុំបានធ្វើតាមផ្លូវតុលាការ។ ច្បាប់បានកំណត់យកសាលាដំបូងនៃលំនៅដ្ឋានរបស់ភាគីដែលពាក់ព័ន្ធនឹងបណ្ដឹង ជាតុលាការមានសមត្ថកិច្ចលើបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល។

ចំពោះជនដែលមានសិទ្ធិទាមទារឱ្យលុបចោលអាពាហ៍ពិពាហ៍ ត្រូវបានកំណត់ជាពីរផ្នែក ប្រសិនបើមូលហេតុនៃការលុបចោលអាពាហ៍ពិពាហ៍មានក្ខណៈជាប្រយោជន៍សាធារណៈ ដូចនេះ ជនដែលមានសិទ្ធិទាមទារលុបចោលអាពាហ៍ពិពាហ៍ តាមបណ្ដឹងទាមទារលុបចោលអាពាហ៍ពិពាហ៍បាន អាចជា ភាគីនីមួយៗនៃអាពាហ៍ពិពាហ៍ផ្ទាល់ ឬជាញាតិសន្ដានរបស់ភាគីនីមួយៗ ឬអាចជាតំណាងអយ្យការ។ រីឯមូលហេតុនៃការលុបចោលអាពាហ៍ពិពាហ៍ដែលមានលក្ខណៈជាប្រយោជន៍ឯកជនវិញ មានតែជនដែលបានរៀបអាពាហ៍ពិពាហ៍ដោយការឆបោក ឬការគម្រាមតែប៉ុណ្ណោះ ទើបអាចទាមទារឱ្យលុបចោលបាន។

[28] ច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល, មាត្រា៣

# ជំពូកទី២

## អានុភាពនៃអាពាហ៍ពិពាហ៍រវាង ពលរដ្ឋខ្មែរ ជាមួយនឹងជនបរទេស នៅកម្ពុជា

# ជំពូកទី២

# អានុភាពនៃអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ ជាមួយនឹងជនបរទេសនៅកម្ពុជា

ក្រោយពីអាពាហ៍ពិពាហ៍មួយត្រូវបានបង្កើតឡើងដោយសមស្រប និងត្រឹមត្រូវតាមច្បាប់រួចរាល់ហើយ នោះនឹងធ្វើឱ្យអានុភាពនៃអាពាហ៍ពិពាហ៍ក៏កើតមានឡើងផងដែរ។ អាពាហ៍ពិពាហ៍ដែលស្របច្បាប់ នឹងនាំឱ្យមានអានុភាពគ្របដណ្តប់ទៅលើទំនាក់ទំនងរវាងសហព័ទ្ធ ដោយព្រមជាមួយនឹងការទទួលបានការការពារ និងការដោះស្រាយពីតុលាការ ប្រសិនបើមានវិវាទ ឬមានហេតុការណ៍ណាមួយកើតឡើងនៅក្នុងចំណងអាពាហ៍ពិពាហ៍។ គួរបញ្ជាក់ផងដែរថា អានុភាពនៃអាពាហ៍ពិពាហ៍ អាចមានភាពខុសគ្នាទៅតាមការកំណត់នៃច្បាប់នាប្រទេសនីមួយៗ ដូចនេះអានុភាពនៃអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ ជាមួយនឹងជនបរទេសអាចមានអានុភាពទៅតាមច្បាប់នៃប្រទេសរបស់សហព័ទ្ធដែលជាជនបរទេសបាន ប្រសិនបើសហព័ទ្ធរស់នៅបរទេស ប៉ុន្តែក្នុងករណីដែលអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេសនោះស្ថិតនៅក្នុងប្រទេសកម្ពុជា ដូចនេះនឹងនាំឱ្យអានុភាពនៃអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេសនោះ ត្រូវស្របតាមច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជាតែប៉ុណ្ណោះ។

## ២.១. សិទ្ធិ និងករណីយកិច្ចរបស់សហព័ទ្ធ

នៅក្នុងសង្គមនៃប្រទេសកម្ពុជា គ្រប់ជនទាំងឡាយមិនថាជានារី ឬបុរសនោះទេ សុទ្ធតែមានសិទ្ធិ និងករណីយកិច្ចដូចៗគ្នាក្នុងនាមជាប្រជាពលរដ្ឋ។ ចំពោះចំណងអាពាហ៍ពិពាហ៍របស់សហព័ទ្ធវិញក៏មិនមានភាពខុសគ្នានោះដែរ ទោះជាសហព័ទ្ធទាំងពីរ គឺជាជនជាតិខ្មែរ ឬសហព័ទ្ធដែលជាជនជាតិខ្មែរ និងជនបរទេសដែលរស់នៅក្នុងប្រទេសកម្ពុជា គឺមាននូវសិទ្ធិ និងករណីយកិច្ចរវាងគ្នា និងគ្នាក្នុងចំណងអាពាហ៍ពិពាហ៍របស់ពួកគេ។

### ២.១.១. សិទ្ធិក្នុងការប្រើប្រាស់នាមត្រកូលរបស់ប្តីប្រពន្ធ

ប្តីប្រពន្ធដែលបានរៀបអាពាហ៍ពិពាហ៍ អាចប្រើនាមត្រកូលរបស់ប្តី ឬប្រពន្ធ ឬក៏ប្រើនាមត្រកូលរបស់ខ្លួនដែលមានមុនពេលរៀបអាពាហ៍ពិពាហ៍ក៏បាន[29]។ តាមស្ថានភាពជាក់ស្តែងនៅក្នុងសង្គម ប្រជាពលរដ្ឋខ្មែរដែលបានរៀបអាពាហ៍ពិពាហ៍រួចហើយ និយមប្រើប្រាស់នាមត្រកូលដើមរបស់ខ្លួនរៀងៗខ្លួន ដែលខុសពីបណ្តាលប្រទេសដទៃទៀតដែលគេនិយមប្រើនាមត្រកូលរបស់ប្តីបន្ទាប់ពីរៀបអាពាហ៍ពិពាហ៍រួចដូចជាប្រទេសអង់គ្លេស ឬសហរដ្ឋអាមេរិកជាដើម។

មូលហេតុដែលប្រជាពលរដ្ឋខ្មែរនិយមប្រើប្រាស់នាមត្រកូលដើមរៀងៗខ្លួន អាចបណ្តាលមកពីការរក្សានាមត្រកូលដើមបែបនេះមានភាពងាយស្រួលដោយពុំចាំបាច់ត្រូវចំណាយពេលវេលាដើម្បីស្នើរសុំផ្លាស់ប្តូរនាម

[29] ក្រមរដ្ឋប្បវេណី, ៨ ធ្នូ ២០០៧, មាត្រា៩៦៥

ត្រកូល និងរក្សានូវអត្តសញ្ញាណដើមរបស់ខ្លួនផងដែរ។ ចំពោះសហព័ទ្ធដែលជាពលរដ្ឋខ្មែរ និងជនបរទេសអាចស្នើរសុំផ្លាស់ប្តូរនាមត្រកូលរបស់ខ្លួនបានដោយដាក់ពាក្យសុំទៅតុលាការ។ ប៉ុន្តែ នៅក្នុងទិដ្ឋភាពជាក់ស្តែងពុំទាន់ឃើញមានការដាក់ពាក្យសុំផ្លាស់ប្តូរនាមត្រកូលដើមរបស់ខ្លួន ដោយយកនាមត្រកូលរបស់សហព័ទ្ធមកប្រើជំនួសវិញនៅឡើយទេ។

### ២.១.២. សិទ្ធិក្នុងការជ្រើសរើសវិជ្ជាជីវៈ

ប្តីប្រពន្ធមានសេរីភាពក្នុងការជ្រើសរើសវិជ្ជាជីវៈដែលខ្លួនពេញចិត្ត និងសាកសមទៅនឹងសមត្ថភាពរបស់ខ្លួន[30]។ ការកំណត់នៅក្នុងច្បាប់បែបនេះហាក់បីដូចជាចង់ផ្តោតសំខាន់ចំពោះស្ត្រី ដោយចង់បង្ហាញអំពីការលើកកម្ពស់ស្ត្រីនៅក្នុងប្រទេសកម្ពុជា និងបង្ហាញថាស្ត្រីសមត្ថភាពដូចទៅនឹងបុរសក្នុងការប្រកបនូវវិជ្ជាជីវៈ ឬបំពេញកិច្ចការ និងអាជីពណាមួយឡើយ។ ប្រសិនបើយើងមើលអតីតភាពនៅក្នុងសង្គម និងនៅតាមបណ្តាប្រទេសជាច្រើនជុំវិញពិភពលោកភាគច្រើនគេតែងផ្តល់តម្លៃ និងផ្តល់អាទិភាពទៅលើបុរសច្រើនជាងស្ត្រី ដែលជាហេតុបង្កើតបានជាទម្លាប់មួយគឺ ការមើលថែរក្សា និងរៀបចំផ្ទះជាតួនាទីរបស់ស្ត្រីដូចឃ្លាមួយពោលថា "ស្ត្រីវិលចង្ក្រានមិនជុំ"។ ក្រឡេកមកមើលបច្ចុប្បន្នវិញ ដោយសារតែមានការលើកកម្ពស់ និងផ្តល់តម្លៃឱ្យស្ត្រី យើងឃើញថាមានវត្តមានរបស់ស្ត្រីនៅក្នុងសង្គមយ៉ាងច្រើន។ លើសពីនេះទៅទៀត កម្ពុជាក៏បានផ្តល់តម្លៃដល់ការងារជាមេផ្ទះ មានតម្លៃស្មើគ្នានឹងការងារនៅខាងក្រៅផ្ទះដែរ[31]។

ហេតុដូចនេះហើយសហព័ទ្ធដែលបានរៀបអាពាហ៍ពិពាហ៍រួចហើយ ទោះបីជាសហព័ទ្ធនោះជាជនបរទេស ឬជាប្រជាពលរដ្ឋខ្មែរក៏ដោយ គឺសុទ្ធតែអាចមានសិទ្ធិជ្រើសរើសប្រកបនូវវិជ្ជាជីវៈដែលខ្លួនពេញចិត្ត ភាគីម្ខាងទៀតពុំមានសិទ្ធិហាមឃាត់ ឬបង្គាប់ឱ្យប្រកបការងារណាមួយឡើយ។ ឧទាហរណ៍ ៖ នារីម្នាក់ជាបុគ្គលិកនៅក្រុមហ៊ុនឯកជនមួយកន្លែង នាងស្រឡាញ់ការងាររបស់នាងណាស់។ ប៉ុន្តែ នៅពេលដែលនាងរៀបអាពាហ៍ពិពាហ៍រួចហើយ ភាគីជាប្តី គាត់គឺជាអ្នកធ្វើការ ឬប្រកបមុខរបរណាមួយ ហើយគាត់មិនអនុញ្ញាតឱ្យប្រពន្ធគាត់ទៅធ្វើការទៀតឡើយ ដោយឱ្យប្រពន្ធគាត់នៅផ្ទះវិញ ទោះបីជាប្រពន្ធសុំធ្វើការយ៉ាងណាក៏គាត់ពុំយល់ព្រមដែរ។ យោងតាមការលើកឡើងឧទាហរណ៍ខាងលើនេះភាគីជាប្តីពុំអាចធ្វើបែបនេះបានឡើយ លុះត្រាតែភាគីជាប្រពន្ធគាត់ជាអ្នកយល់ដោយខ្លួនឯងដោយគ្មានការបង្ខិតបង្ខំ។

---

[30] ក្រមរដ្ឋប្បវេណី, ៨ ធ្នូ ២០០៧, មាត្រា៩៦៧

[31] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ២៤ កញ្ញា ១៩៩៣, មាត្រា៣៦ វាក្យខណ្ឌទី៣

### ២.១.៣. សិទ្ធិក្នុងការចូលរួមសកម្មភាពសង្គម

ក្រៅពីសិទ្ធិដែលសហព័ទ្ធត្រូវមានរវាងគ្នានឹងគ្នា ហើយនោះ សហព័ទ្ធក៏មានសិទ្ធិចូលរួមនៅក្នុងសកម្មភាពសង្គម នយោបាយ វប្បធម៌ រៀងៗខ្លួនផងដែរ[32]។ ក្នុងការកំណត់បែបនេះ គឺមានលក្ខណៈសមស្របទៅនឹងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា១៩៩៣[33]។

ជាធម្មតាប្រទេសនីមួយៗ តែងតែមានភាពខុសគ្នាក្នុងសកម្មភាពសង្គម នយោបាយ ឬវប្បធម៌ នៅក្នុងករណីដែលប្រជាពលរដ្ឋខ្មែរ បានរៀបអាពាហ៍ពិពាហ៍ជាមួយនឹងបរទេស សហព័ទ្ធដែលជាប្រជាពលរដ្ឋខ្មែរនៅតែអាចចូលរួមយ៉ាងសកម្មក្នុងសកម្មភាពទាំងនេះ ដោយសហព័ទ្ធដែលជាបរទេសពុំមានសិទ្ធិហាមឃាត់ក្នុងការចូលរួមនោះឡើយ រីឯសហព័ទ្ធដែលជាប្រជាពលរដ្ឋខ្មែរក៏ពុំមានសិទ្ធិហាមឃាត់ការចូលរួមក្នុងសកម្មភាពសង្គមរបស់សហព័ទ្ធដែលជាជនបរទេសដែរ។

### ២.១.៤. ករណីយកិច្ចរួមរស់នឹងគ្នា សហការ និងសង្គ្រោះគ្នាទៅវិញទៅមក

សហព័ទ្ធដែលបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ត្រូវរួមរស់ជីវភាពជាមួយគ្នា ហើយត្រូវសហការ និងសង្គ្រោះគ្នាទៅវិញទៅមក[34]។ ប្តីប្រពន្ធ ត្រូវមើលថែ រួមរស់ជាមួយគ្នាបង្កើតកូនចៅដើម្បីបន្តពូជពង្សវង្សត្រកូលមានជីវភាពជាក់លាក់មួយរួមគ្នាដើម្បីឱ្យគ្រួសារមានសុភមង្គល។ ក្រៅពីនេះ ប្តីប្រពន្ធគប្បីលើកទឹកចិត្ត សហការគ្នាទៅវិញទៅមកក្នុងការបំពេញកិច្ចការងារដើម្បីជីវភាពប្រចាំថ្ងៃ និងមានករណីយកិច្ចសង្គ្រោះគ្នាទៅវិញទៅមកក្នុងគ្រាមានអាសន្ន ឬស្ថានភាពចាំបាច់ណាមួយ។

## ២.២. ទំនាក់ទំនងចំពោះទ្រព្យសម្បត្តិប្តីប្រពន្ធ

បន្ទាប់ពីអាពាហ៍ពិពាហ៍បានកើតឡើងរួចហើយ ក្រៅពីមានអានុភាពពាក់ព័ន្ធទៅនឹងសិទ្ធិ និងករណីយកិច្ចហើយនោះ អាពាហ៍ពិពាហ៍នោះ ក៏នាំឱ្យមានអានុភាពចំពោះទ្រព្យសម្បត្តិផងដែរ។ បើយើងក្រឡេកទៅមើលនៅក្នុងក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ បានបង្ហាញអំពីការកំណត់នៃប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធត្រូវបានបែងចែកជាពីរ គឺ ប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា និងប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់។

### ២.២.១. ប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា

ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមកិច្ចសន្យា នឹងកើតមានឡើងក្នុងករណីដែលសហព័ទ្ធបានព្រមព្រៀងគ្នាធ្វើកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ។ ប្តីប្រពន្ធអាចធ្វើកិច្ចសន្យាអំពីទំនាក់ទំនងទ្រព្យសម្បត្តិ នៅមុន ឬក្រោយ

[32] ក្រមរដ្ឋប្បវេណី, ៨ ធ្នូ ២០០៧, មាត្រា៩៦៧

[33] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ២៤ កញ្ញា ១៩៩៣, មាត្រា៣៥ វាក្យខណ្ឌទី១

[34] ក្រមរដ្ឋប្បវេណី, ៨ ធ្នូ ២០០៧, មាត្រា៩៦៦

រៀបអាពាហ៍ពិពាហ៍បានកើតឡើង។ ការបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ គឺជាជម្រើសរបស់សហព័ទ្ធ ហើយនៅក្នុងស្ថានភាពជាក់ស្តែងនៃទំនាក់ទំនងរបស់ប្តីប្រពន្ធមានលក្ខណៈច្រើនបែបច្រើនយ៉ាង ដូចនេះ ជម្រើសរបស់ប្តីប្រពន្ធអាចមានលក្ខណៈបត់បែនសមស្របទៅតាមភាពចាំបាច់ជាក់ស្តែង។ ត្បិតតែមានការ បញ្ញត្តិអំពីសេរីភាពរបស់ប្តីប្រពន្ធ ក្នុងការធ្វើកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធក៏ដោយ ប៉ុន្តែ កិច្ចសន្យានោះពុំត្រូវធ្វើ ឡើងដោយផ្ទុយនឹងបញ្ញត្តិស្តីពីសិទ្ធិទាមទារអាហារកិច្ច និងភាគបម្រុងបានឡើយ[35]។ ការបង្កើតកិច្ចសន្យាទ្រព្យ សម្បត្តិប្តីប្រពន្ធ មានគោលបំណងដើម្បីទប់ស្កាត់វិវាទលើទំនាក់ទំនងទ្រព្យសម្បត្តិ និងបញ្ជាក់ឱ្យបានច្បាស់អំពី ទំនាក់ទំនងសិទ្ធិ និងករណីយកិច្ចរបស់ប្តីប្រពន្ធ។ ប្រសិនបើសហព័ទ្ធពុំបានបង្កើតកិច្ចសន្យាពិសេសអំពីទ្រព្យ សម្បត្តិប្តីប្រពន្ធនោះទេ ទំនាក់ទំនងទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធនឹងត្រូវអនុលោមតាមប្រព័ន្ធទ្រព្យសម្បត្តិដែល ច្បាប់បានកំណត់[36]។

កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ចាំបាច់ត្រូវធ្វើលាយល័ក្ខណ៍អក្សរ និងត្រូវធ្វើការចុះបញ្ជីដើម្បីអាចយក កិច្ចសន្យានោះមកតតាំងជាមួយនឹងតតិយជនបាន[37]។ ការកំណត់បែបនេះដោយសារតែកិច្ចសន្យាទ្រព្យសម្បត្តិ ប្តីប្រពន្ធមានឥទ្ធិពលយ៉ាងខ្លាំងទៅលើទំនាក់ទំនងនៃសិទ្ធិ និងករណីយកិច្ចលើទ្រព្យសម្បត្តិរវាងប្តីប្រពន្ធ ដែល មិនអាចធ្វើឡើងបានដោយត្រឹមតែពាក្យសំដីបានឡើយ។ ក្រៅពីការបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធជា ទម្រង់លាយល័ក្ខអក្សរហើយនោះ ត្រូវដាក់ពាក្យសុំចុះបញ្ជីកិច្ចសន្យានោះទៅស្ថាប័នមានសមត្ថកិច្ចលើការចុះ បញ្ជី[38]។ ចំពោះនីតិវិធីស្តីពី ការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ត្រូវអនុលោមតាមប្រកាសស្តីពីនីតិវិធីចុះ បញ្ជីទ្រព្យ សម្បត្តិប្តីប្រពន្ធ ឆ្នាំ២០១៤ ហើយយោងតាមកថាខណ្ឌទី១ ប្រការ៤ នៃប្រកាសនេះ ចែងថា នាយក ដ្ឋាននៃកិច្ចការរដ្ឋប្បវេណី មានសមត្ថកិច្ចចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ។

### ២.២.២. ប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់

ប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់ គឺជាប្រព័ន្ធទ្រព្យសម្បត្តិមួយដែលច្បាប់ឱ្យប្តីប្រពន្ធអនុវត្ត នៅពេលដែលពួកគេមិនបានជ្រើសរើសប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា។ ប្តីប្រពន្ធ ត្រូវមានចំណែកបន្ទុករួមគ្នា លើសោហ៊ុយអាពាហ៍ពិពាហ៍ ដែលកើតមាននៅក្នុងចំណងអាពាហ៍ពិពាហ៍របស់ខ្លួន ដើម្បីថែទាំជីវភាពរួមនៃអា ពាហ៍ពិពាហ៍។ ចំណែកបន្ទុកនៃសោហ៊ុយអាពាហ៍ពិពាហ៍ គឺតម្រូវឱ្យប្តីប្រពន្ធចែករំលែកសោហ៊ុយទៅតាមទ្រព្យ សម្បត្តិ ប្រាក់ចំណូល ឬមុខរបរ របស់ប្តីប្រពន្ធជាដើម[39]។ សោហ៊ុយអាពាហ៍ពិពាហ៍គឺជាសោហ៊ុយចាំបាច់

[35] ក្រមរដ្ឋប្បវេណី, ៨ ធ្នូ ២០០៧, មាត្រា៩៦៩ វាក្យខណ្ឌទី១

[36] ក្រមរដ្ឋប្បវេណី, ៨ ធ្នូ ២០០៧, មាត្រា៩៦៩ វាក្យខណ្ឌទី២

[37] ក្រមរដ្ឋប្បវេណី, ៨ ធ្នូ ២០០៧, មាត្រា៩៧០

[38]ប្រកាសស្តីពី នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ, ប្រការ៤

[39] ក្រមរដ្ឋប្បវេណី, ៨ ធ្នូ ២០០៧, មាត្រា៩៧១

សម្រាប់ចំណាយលើជីវភាពប្រចាំថ្ងៃ ថ្លៃព្យាបាល ការសិក្សា និងការថែទាំកូន។ នៅក្នុងប្រព័ន្ធទ្រព្យសម្បត្តិដែលច្បាប់កំណត់ បានបែងចែកទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធជា ២គឺ ទ្រព្យសម្បត្តិដោយឡែក និងទ្រព្យសម្បត្តិរួម។

**២.២.២.១. ទ្រព្យសម្បត្តិដោយឡែក**

ទ្រព្យសម្បត្តិដោយឡែក គឺជាទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់ភាគីដែលជាសហព័ទ្ធ។ ទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់ភាគីដែលជាសហព័ទ្ធ គឺជាទ្រព្យសម្បត្តិដែលសហព័ទ្ធមាននៅមុនពេលដែលខ្លួនរៀបអាពាហ៍ពិពាហ៍ ឬជាទ្រព្យសម្បត្តិដែលទទួលបានតាមរយៈ ប្រទានកម្ម សន្តតិកម្ម អច្ច័យទាននៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ និងទ្រព្យសម្បត្តិជាតម្លៃតប ដែលទទួលបានពីការចាត់ចែងទ្រព្យសម្បត្តិខាងលើនេះ[40]។

សហព័ទ្ធទាំងពីរអាចប្រើប្រាស់ និងចាត់ចែងទ្រព្យសម្បត្តិដោយឡែករបស់ខ្លួនបានដោយពុំចាំបាច់មានការយល់ព្រមពីភាគីម្ខាងទៀតនោះទេ។ សហព័ទ្ធនីមួយៗ មានសិទ្ធិប្រើប្រាស់ ទទួលផលប្រយោជន៍ និងគ្រប់គ្រងទ្រព្យសម្បត្តិរបស់ខ្លួនបានរៀងៗខ្លួន។

**២.២.២.២. ទ្រព្យសម្បត្តិរួម**

ទ្រព្យសម្បត្តិរួម គឺជាទ្រព្យសម្បត្តិដែលប្តីប្រពន្ធទាំងសងខាង ឬ តែម្ខាងទទួលបាននៅក្នុងអំឡុងពេលរៀបអាពាហ៍ពិពាហ៍ លើកលែងតែទ្រព្យសម្បត្តិដោយឡែកដែលបានចែងនៅក្នុងចំណុច ខ និង ចំណុចគ នៃមាត្រា ៩៧២ នៃក្រមរដ្ឋប្បវេណីតែប៉ុណ្ណោះ[41]។ ឧទាហរណ៍ដូចជា ទ្រព្យសម្បត្តិទាំងឡាយណាដែលសហព័ទ្ធរកបានដូចជា ប្រាក់ខែរបស់ប្តីប្រពន្ធ និងចំណូលពីការរកស៊ីរបស់ប្តីប្រពន្ធ ជាដើម ដែលបានទទួលក្នុងចំណងអាពាហ៍ពិពាហ៍។

សហព័ទ្ធមានសិទ្ធិស្មើគ្នាក្នុងការប្រើប្រាស់ ទទួលផលប្រយោជន៍ និងគ្រប់គ្រងទ្រព្យសម្បត្តិរួមដោយសហការគ្នា[42]។ សហព័ទ្ធមានសិទ្ធិប្រើប្រាស់ទ្រព្យសម្បត្តិរួមនោះ នៅក្នុងទំហំដែលចាំបាច់ដោយផ្អែកលើការចាំបាច់នៅក្នុងជីវភាព[43]។ ក្នុងករណីដែលដែលពុំអាចពិភាក្សាគ្នាបានក្នុងការគ្រប់គ្រង ឬប្រើប្រាស់ទ្រព្យសម្បត្តិរួមប្តីប្រពន្ធនោះទេ ភាគីម្ខាងទៀតអាចទាមទារទៅតុលាការឱ្យធ្វើការចាត់ចែងបាន[44]។

**២.២.២.៣. ការចាត់ចែងទ្រព្យសម្បត្តិរួម និងការអាស្រ័យនៅទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធ**

**ក. ការចាត់ចែងទ្រព្យសម្បត្តិរួម**

---

[40] ក្រមរដ្ឋប្បវេណី, ៨ ធ្នូ ២០០៧, មាត្រា៩៧២

[41] ក្រមរដ្ឋប្បវេណី, ៨ ធ្នូ ២០០៧, មាត្រា៩៧៣

[42] ក្រមរដ្ឋប្បវេណី, ៨ ធ្នូ ២០០៧, មាត្រា៩៧៤

[43] ក្រមរដ្ឋប្បវេណី, ៨ ធ្នូ ២០០៧, មាត្រា៩៧៤, វាក្យខណ្ឌទី២

[44] ក្រមរដ្ឋប្បវេណី, ៨ ធ្នូ ២០០៧, មាត្រា៩៧៤, វាក្យខណ្ឌទី៤

ត្បិតតែទ្រព្យសម្បត្តិរួម គឺជាទ្រព្យសម្បត្តិដែលសហព័ទ្ធទទួលបានក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ហើយមានសិទ្ធិប្រើប្រាស់ គ្រប់គ្រង និងចាត់ចែងលើទ្រព្យសម្បត្តិរួមនោះក៏ដោយ ក៏សហព័ទ្ធមិនអាចយកវត្ថុដែលជាទ្រព្យសម្បត្តិរួមនោះយកទៅលក់ ឬចាត់ចែងផ្សេងទៀតបានឡើយ ប្រសិនបើគ្មានការយល់ព្រមពីសហព័ទ្ធម្ខាងទៀត[45]។ ប៉ុន្តែ ក៏មានករណីលើកលែងផងដែរ ប្រសិន បើមានស្ថានភាពណាមួយដែលមិនអាចចៀសវៀងបាន សម្រាប់ការថែទាំជីវភាពរួមក្នុងចំណងអា ពាហ៍ពិពាហ៍ និងដើម្បីថែរក្សាជីវភាពរស់នៅប្រចាំថ្ងៃ នោះប្តី ឬប្រពន្ធណាម្ខាងអាចចាត់ចែងដោយឯកតោភាគីលើទ្រព្យសម្បត្តិរួមនោះបានដោយមានការយល់ព្រមពីតុលាការ[46]។

ប្រសិនបើប្តី ឬប្រពន្ធម្ខាងណា ដែលបានលក់ ឬធ្វើការចាត់ចែងផ្សេងទៀតលើទ្រព្យសម្បត្តិរួមនោះដោយគ្មានការយល់ព្រមពីសហព័ទ្ធម្ខាងទៀត ឬការអនុញ្ញាតពីតុលាការទេ នោះសហព័ទ្ធម្ខាងទៀតដែលជាអ្នកមិនយល់ព្រមឱ្យលក់ ឬចាត់ចែងផ្សេងទៀតលើទ្រព្យសម្បត្តិរួមនោះ អាចទាមទារទៅតុលាការឱ្យលុបចោលនូវការចាត់ចែងនោះបាន[47]។ ការទាមទារទៅតុលាការឱ្យលុបចោលនូវការចាត់ចែងនោះ ត្រូវធ្វើឡើងនៅក្នុងអំឡុងពេល ២ ឆ្នាំ និងអំឡុងពេល ១ ឆ្នាំ ចំពោះទ្រព្យសម្បត្តិដែលជាចលនវត្ថុ ដោយគិតចាប់ពីពេលដែលសហព័ទ្ធម្ខាងទៀតនោះដឹងពីការចាត់ ចែងនោះ។

### ខ. ការអាស្រ័យនៅទ្រព្យសម្បត្តិដោយឡែក

ប្តី ឬប្រពន្ធម្ខាងទៀត អាចអាស្រ័យនៅអចលនវត្ថុដែលជាទ្រព្យសម្បត្តិដោយឡែករបស់ភាគីម្ខាងទៀតបាន ហើយដែលត្រូវបានប្រើសម្រាប់ការអាស្រ័យនៅរបស់គ្រួសារបាន[48]។ ទោះបីជាសហព័ទ្ធម្ខាង បានចាត់ចែងទ្រព្យសម្បត្តិដោយឡែកដែលជាអចលនវត្ថុនោះក៏ដោយ ក៏សហព័ទ្ធម្ខាងទៀតនៅតែអាចបន្តការអាស្រ័យនៅអចលនវត្ថុនោះបានដដែល[49]។

### ២.២.២.៤. ការទទួលខុសត្រូវដោយសាមគ្គីចំពោះកាតព្វកិច្ច

ប្តីប្រពន្ធត្រូវទទួលខុសត្រូវដោយសាមគ្គីភាព ចំពោះកាតព្វកិច្ចដែលកំណត់ដូចខាងក្រោម[50]៖

- សោហ៊ុយដើម្បីរក្សាជីវភាពរួមរបស់ប្តីប្រពន្ធ និងសោហុយដើម្បីការអប់រំ ឬការព្យាបាល ថែទាំកូន ជាអាទិ៍។

---

[45] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, ប្រកាសឱ្យប្រើនៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា៩៧៦ វាក្យខ័ណ្ឌទី១

[46] ក្រមរដ្ឋប្បវេណី, ៨ ធ្នូ ២០០៧, មាត្រា៩៧៦ វាក្យខណ្ឌទី២

[47] ក្រមរដ្ឋប្បវេណី, ៨ ធ្នូ ២០០៧, មាត្រា៩៧៦ វាក្យខណ្ឌទី៣

[48] ក្រមរដ្ឋប្បវេណី, ៨ ធ្នូ ២០០៧, មាត្រា៩៧៧

[49] ក្រមរដ្ឋប្បវេណី, ៨ ធ្នូ ២០០៧, មាត្រា៩៧៧

[50] ក្រមរដ្ឋប្បវេណី, ៨ ធ្នូ ២០០៧, មាត្រា៩៧៥

- កាតព្វកិច្ច និងករណីយកិច្ចផ្សេងៗទៀត ដែលប្តី ឬប្រពន្ធទាំងសងខាងបានព្រមព្រៀងតាមលិខិតជាលាយល័ក្ខណ៍អក្សរ ជាមួយម្ចាស់បំណុល នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ឬកាតព្វកិច្ច និងករណីយកិច្ចផ្សេងៗទៀត ដែលប្តី ឬប្រពន្ធណាម្ខាងបានទទួលបន្ទុក ដោយមានការយល់ព្រមតាមលិខិតជាលាយល័ក្ខណ៍អក្សរពីប្តី ឬប្រពន្ធម្ខាងទៀត ក្នុងអំឡុងពេលអាពាហ៍ពិពាហ៍។ មានន័យថាសហព័ទ្ធក៏ត្រូវទទួលខុសត្រូវនូវបំណុលដោយសាមគ្គីគ្នា ចំពោះម្ចាស់បំណុល ក្នុងករណីជាភាគីប្តី ឬប្រពន្ធតែម្ខាងគឺជាអ្នកទទួលខ្ចី ប៉ុន្តែ ការខ្ចីនោះមានការព្រមព្រៀងពីភាគីដែលជាប្តី ឬប្រពន្ធម្ខាងទៀតតាមរយៈលិខិតជាលាយលក្ខណ៍អក្សរ ក្នុងអំឡុងពេលអាពាហ៍ពិពាហ៍។
- សោហ៊ុយដើម្បីគ្រប់គ្រង និងរក្សាទ្រព្យសម្បត្តិរួម។

ដូចបានរៀបរាប់ខាងលើនេះ រាល់កាតព្វកិច្ចដែលបានកើតឡើងខុសពីការកំណត់នេះ នោះសហព័ទ្ធនឹងត្រូវទទួលខុសត្រូវតាមផ្លូវច្បាប់ តែចំពោះសហព័ទ្ធម្ខាងដែលបានបង្កើតកាតព្វកិច្ច។ ករណីនេះ មានន័យថាម្ចាស់បំណុល មិនអាចទាមទារនូវសិទ្ធកំណត់ជាក់លាក់ណាមួយទៅសហព័ទ្ធមិនមានភាពពាក់ព័ន្ធទៅនឹងកាតព្វកិច្ចនោះទេ។

## ២.៣. ទំនាក់ទំនងចំពោះបុត្តភាព

ដោយយោងតាមសទ្ទានុក្រមនៃក្រមរដ្ឋប្បវេណីពាក្យថា «បុត្តភាព» មានន័យថា ក្រសែញាតិដែលទាក់ទងពីឪពុកម្តាយទៅកូនបង្កើតរបស់ខ្លួន។ ហេតុនេះហើយ ទំនាក់ទំនងបុត្តភាព គឺចង់សំដៅដល់ទំនាក់ទំនងដូចជាសិទ្ធិ និងករណីយកិច្ចរបស់ឪពុកម្តាយ ទៅកូនបង្កើតរបស់ខ្លួន។ ការកំណត់បុត្តភាព ត្រូវបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណី។

### ២.៣.១. វិធាននៅក្នុងការកំណត់ឋានៈជាឪពុកម្តាយ

នៅក្នុងក្រមរដ្ឋប្បវេណីបានកំណត់ថា ស្ត្រីដែលបានសម្រាលកូន គឺជាម្តាយនៃកូននោះ[51]។ ជាទូទៅវាជារឿងដែលធម្មតាទេដែលស្ត្រីដែលជាអ្នកសម្រាលកូនគឺជាម្តាយនៃកូននោះ ការកំណត់បែបនេះគឺមានគោលបំណងដើម្បីឱ្យមានយ៉ាងហោចណាស់ម្តាយម្នាក់ សម្រាប់ទ្រទ្រង់ដល់សុខុមាលភាពរបស់កូននោះដែរ[52]។ ចំពោះការកំណត់បិតុភាពវិញ ហាក់មានភាពស្មុគស្មាញជាងការកំណត់មាតុភាព។ ជាទូទៅ កូនដែលនៅក្នុងគភ៌ប្រពន្ធនៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ត្រូវបានកំណត់ថាជាកូនរបស់ប្តីនោះ[53]។ ប៉ុន្តែនៅក្នុងករណីខ្លះ នាំឱ្យត្រូវមានការពិចារណាចំពោះបិតុភាព ហេតុដូចនេះហើយទើបច្បាប់បានកំណត់អំពីបិតុភាព ដោយ

[51] ក្រមរដ្ឋប្បវេណី, ៨ ធ្នូ ២០០៧, មាត្រា៩៨៧

[52] សេចក្តីកំណត់ក្រមរដ្ឋប្បវេណី ភាគទី៥-គន្លឹទី៧, មាត្រា៩៨៧

[53] ក្រមរដ្ឋប្បវេណី, ៨ ធ្នូ ២០០៧, មាត្រា៩៨៨, វាក្យខណ្ឌទី១

សន្មតថាកូនដែលបានកើតនៅក្រោយអំឡុងពេល ១៨០ ថ្ងៃ គិតចាប់ពីថ្ងៃដែលអាពាហ៍ពិពាហ៍ត្រូវបានបង្កើតឡើង ឬអំឡុងពេល ៣០០ ថ្ងៃ គិតចាប់ពីថ្ងៃដែលអាពាហ៍ពិពាហ៍ត្រូវបានរំលាយ ឬលុបចោល ត្រូវសន្មតថាកូនដែលនៅក្នុងគភ៌នោះ គឺជាកូនដែលមាននៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍[54]។ នៅក្នុងករណីដែលស្ត្រីដែលបានរៀបអាពាហ៍ពិពាហ៍ថ្មី ផ្ទុយនឹងបញ្ញត្តិនៃមាត្រា ៩៥០ (អំឡុងពេលហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍ថ្មីទៀត) បានបង្កើតកូន នោះកូនដែលបានកើតមកនោះត្រូវបានសន្មតថាជាកូនរបស់ប្តីដែលបានរៀបអាពាហ៍ពិពាហ៍ក្រោយនោះ[55]។ ប៉ុន្តែ ការសន្មតក្នុងករណីខាងលើនេះមិនបានកំណត់យ៉ាងដាច់ខាតថាប្តីដែលរៀបអាពាហ៍ពិពាហ៍ក្រោយនោះ ត្រូវតែទទួលការសន្មតបិតុភាពនេះនោះទេ ប្រសិនបើប្តីដែលបានរៀបអាពាហ៍ពិពាហ៍ក្រោយមិនចង់ទទួលស្គាល់ការសន្មតនេះ អាចដាក់ពាក្យបណ្តឹងបដិសេធបិតុភាពបាន។ ក្នុងពេលដែលបុត្តភាពត្រូវបានកំណត់ និងមិនមានការបដិសេធបុត្តភាពនោះទេ ប្តីប្រពន្ធដែលបានកំណត់ខាងលើនេះត្រូវសន្មតថាជាឪពុកម្តាយរបស់កូន។

**២.៣.២. អំណាចមេបា**

គ្រប់ឪពុកម្តាយទាំងអស់មានករណីយកិច្ចក្នុងការចិញ្ចឹម ថែរក្សា ការពារ និងអប់រំកូនរបស់ខ្លួនឱ្យក្លាយទៅជាពលរដ្ឋល្អ[56]។ លើសពីនេះទៅទៀត ឪពុក ឬម្តាយមានករណីយកិច្ចត្រូវសុំចុះកំណើតរបស់កូន នៅសាលាឃុំសង្កាត់នៃលំនៅដ្ឋានរបស់ឪពុកម្តាយ ក្នុងអំឡុងពេល៣០ថ្ងៃ គិតចាប់ពីថ្ងៃដែលកូននោះកើត[57]។ ក្នុងការកំណត់ការចុះកំណើតរបស់កូនខាងលើនេះ បានសង្កត់ធ្ងន់ទៅលើពាក្យថា «ឪពុក ឬម្តាយ» ដែលចង់បង្ហាញថាច្បាប់ពុំបានកំណត់ដាច់ខាតចំពោះការសុំចុះកំណើត គឺតម្រូវឱ្យមានវត្តមានទាំងឪពុក និងម្តាយនោះទេ។ ការបញ្ញត្តិបែបនេះ គឺដើម្បីផ្តល់ភាពងាយស្រួលចំពោះម្តាយដែលទើបនឹងសម្រាលកូនហើយ។ នៅក្នុងករណីប្រសិនបើឪពុកម្តាយពុំបានចុះកំណើតកូនរបស់ខ្លួន ដោយពុំមានហេតុផលត្រឹមត្រូវក្នុងអំឡុងពេល ៣០ ថ្ងៃនៃការកំណត់នេះទេ នឹងត្រូវផាកពិន័យស៊ីវិលជាប្រាក់ ដែលមានចំនួនមិនលើសពី ១ ម៉ឺនរៀល[58]។

ឪពុកម្តាយដែលមានចំណងអាពាហ៍ពីពាហ៍ ត្រូវប្រើប្រាស់អំណាចមេបាដោយសហការគ្នា ប៉ុន្តែ ក្នុងករណីដែលឪពុក ឬម្តាយម្ខាងពុំអាចប្រើប្រាស់អំណាចមេបាបានទេ នោះឪពុក ឬម្តាយម្ខាងទៀតត្រូវត្រូវប្រើប្រាស់អំណាចមេបានោះ[59]។ ករណីដែលឪពុក ឬម្តាយម្ខាងពុំអាចប្រើប្រាស់អំណាចមេបាដោយសហការ

[54] ក្រមរដ្ឋប្បវេណី, ៨ ធ្នូ ២០០៧, មាត្រា៩៨៨, វាក្យខណ្ឌទី២
[55] ក្រមរដ្ឋប្បវេណី, ៨ ធ្នូ ២០០៧, មាត្រា៩៨៨, វាក្យខណ្ឌទី៣
[56] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា,២៤ កញ្ញា ១៩៩៣, មាត្រា៤៧
[57] ក្រមរដ្ឋប្បវេណី, ៨ ធ្នូ ២០០៧, មាត្រា៩៨៥ វាក្យខណ្ឌទី១
[58] ក្រមរដ្ឋប្បវេណី, ៨ ធ្នូ ២០០៧, មាត្រា៩៨៥ វាក្យខណ្ឌទី២
[59] ក្រមរដ្ឋប្បវេណី, ៨ ធ្នូ ២០០៧, មាត្រា១០៣៦

ជាមួយឪពុក ឬម្ដាយម្ខាងទៀតបាន អាចមានករណីដូចជាឪពុក ឬម្ដាយនោះបាត់បង់សតិ បាត់ខ្លួន ឬមិនអាចទាក់ទងបាន ព្រមទាំងករណីដែលបញ្ញត្តិច្បាប់មិនអនុញ្ញាតឱ្យឪពុក ឬម្ដាយនោះប្រើប្រាស់អំណាចមេបាដាដើម។

## ២.៤. ការទទួលបានសញ្ជាតិតាមរយៈការរៀបអាពាហ៍ពិពាហ៍

ជនណាដែលមានសញ្ជាតិខ្មែរ គឺជាប្រជាពលរដ្ឋខ្មែរ[60]។ ជនដែលនឹងទទួលបានសញ្ជាតិខ្មែរពីកំណើតត្រូវបានចែកចេញជា ២ ករណីគឺៈ ករណីនៃការទទួលបានការសញ្ជាតិខ្មែរ ទោះបីជាកើតនៅទីណាក៏ដោយ និងករណីនៃការទទួលបានសញ្ជាតិខ្មែរ ដោយបានកើតនៅក្នុងព្រះរាជាណាចក្រកម្ពុជា[61] ។

- ករណីនៃការទទួលបានការសញ្ជាតិខ្មែរ ទោះបីជាកើតនៅទីណាក៏ដោយ មានដូចជាៈ
  - កូនមានខាន់ស្លា ដែលកើតមកពីឪពុក ឬម្ដាយដែលមានសញ្ជាតិខ្មែរ។
  - កូនឥតមានខាន់ស្លា ដែលកើតមកពីឪពុក ឬម្ដាយដែលមានសញ្ជាតិខ្មែរនោះទទួលស្គាល់។
  - កូនដែលឪពុក ឬម្ដាយមិនទទួលស្គាល់ ប៉ុន្តែ តុលាការបានចេញសាលក្រមថាកូននោះពិតជាកូនដែលកើតចេញពីឪពុកម្ដាយដែលមានសញ្ជាតិខ្មែរ។
- ករណីនៃការទទួលបានសញ្ជាតិខ្មែរ ដោយបានកើតនៅក្នុងព្រះរាជាណាចក្រកម្ពុជា មានដូចជាៈ
  - កូនដែលបានកើតពីឪពុក និងម្ដាយបរទេស ដែលកើត និងរស់នៅដោយស្របច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។
  - កូនដែលបានកើតពីឪពុក ម្ដាយដែលមិនស្គាល់ និងកូនទើបនឹងកើត ដែលត្រូវបានគេរើសបាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបានចាត់ទុកថាកើតនៅក្នុងព្រះរាជាណាចក្រកម្ពុជាដែរ។

ចំពោះស្ត្រី ឬបុរសដែលជាជនបរទេស ដែលយកប្ដី ឬប្រពន្ធជាពលរដ្ឋខ្មែរ ហើយបានរៀបអាពាហ៍ពិពាហ៍តាមប្រពៃណី និងបានបំពេញលក្ខខណ្ឌត្រឹមត្រូវតាមច្បាប់ អាចទាមទារសញ្ញាតិខ្មែរបាន។

### ២.៤.១. លក្ខខណ្ឌក្នុងការទាមទារសញ្ជាតិខ្មែរតាមរយៈការរៀបអាពាហ៍ពិពាហ៍

ជនបរទេសដែលបានរៀបអាពាហ៍ពិពាហ៍ជាមួយពលរដ្ឋខ្មែរ ហើយចង់ទាមទារសញ្ជាតិខ្មែរដោយអាពាហ៍ពិពាហ៍នោះ អាចទាមទារសញ្ជាតិខ្មែរបាន ប៉ុន្តែ ត្រូវបំពេញលក្ខខណ្ឌមួយចំនួន។

ជនបរទេស អាចសុំទាមទារសញ្ជាតិខ្មែរដោយការរៀបអាពាហ៍ពិពាហ៍ជាមួយពលរដ្ឋខ្មែរបាន លុះត្រាតែស្ត្រី និងបុរសនោះបានរស់នៅជាមួយគ្នារយៈពេល ០៣ ឆ្នាំ ក្រោយពេលចុះបញ្ជីអាពាហ៍ពិពាហ៍ និងបានស្នាក់នៅយ៉ាងហោចណាស់រយៈពេល ១២ (ដប់ពីរ) ខែ ពេញលេញនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងត្រូវបាន

[60] ច្បាប់ស្តីពីសញ្ជាតិ, អនុម័តកាលពីថ្ងៃទី២១ មិថុនា ឆ្នាំ២០១៨, មាត្រា៦
[61] ច្បាប់ស្តីពីសញ្ជាតិ, អនុម័តកាលពីថ្ងៃទី២១ មិថុនា ឆ្នាំ២០១៨, មាត្រា៩

អនុញ្ញាតឱ្យសុំទាមទារសញ្ជាតិខ្មែរជាចង្កោមគ្រួសារចំពោះជនបរទេសជាម្ដាយ ឬឪពុកដែលមានកូនជាអនីតិជន[62]។

លើសពីនេះទៅទៀត ជនបរទេសដែលអាចសុំទាមទារសញ្ជាតិខ្មែរដោយអាពាហ៍ពិពាហ៍បានលុះត្រាតែបានបំពេញលក្ខខណ្ឌដូចតទៅ[63]៖

- មានគំនិត មារយាទ និងសីលធម៌ល្អ។
- ពុំដែលមានទោសពីបទឧក្រិដ្ឋ ឬបទមជ្ឈិមណាមួយ។
- មានទីលំនៅក្នុងព្រះរាជាណាចក្រកម្ពុជានៅពេលដាក់ពាក្យសុំទាមទារសញ្ជាតិខ្មែរ ។
- ចេះនិយាយភាសាខ្មែរ ចេះអក្សរខ្មែរ និងយល់ដឹងពីប្រវត្តិសាស្ត្រខ្មែរខ្លះៗ ។
- មានបញ្ញា និងកាយសម្បទាដែលមិននាំឱ្យមានគ្រោះថ្នាក់ ឬនាំឱ្យមានបន្ទុកដល់ជាតិ ។

នៅក្នុងករណីដែលអាជ្ញាធរមានសមត្ថកិច្ច ធ្វើការបដិសេធនូវការទាមទារសញ្ជាតិខ្មែររបស់ជនបរទេសនោះ សាមីខ្លួនមានសិទ្ធិប្ដឹងតវ៉ា។

### ២.៤.២. នីតិវិធីនៃការទាមទារសញ្ជាតិខ្មែរតាមរយៈអាពាហ៍ពិពាហ៍

ចំពោះជនបរទេសដែលចង់ទាមទារសញ្ជាតិខ្មែរដោយអាពាហ៍ពិពាហ៍ ក្រៅពីត្រូវមានលក្ខណៈសមស្របទៅតាមលក្ខខណ្ឌដើម្បីទាមទារសញ្ជាតិខ្មែរខាងលើហើយនោះ ជនបរទេសត្រូវទៅដាក់ពាក្យសុំទាមទារសញ្ជាតិដើម្បីទទួលបានសញ្ជាតិខ្មែរ។ ជនបរទេសដែលចង់ដាក់ពាក្យសុំទាមទារសញ្ជាតិខ្មែរនោះ ត្រូវទៅបំពេញបែបបទនៅអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មនៃក្រសួងមហាផ្ទៃ[64]។ ជនបរទេសដែលទាមទារសញ្ជាតិខ្មែរ ត្រូវមានវត្តមាននៅក្នុងព្រះរាជាណាចក្រកម្ពុជានៅពេលដែលដាក់ពាក្យសុំ និងត្រូវបំពេញបែបបទមួយចំនួន៖[65]

- ពាក្យសុំទាមទារសញ្ជាតិខ្មែរចំនួន ០២ ច្បាប់
- លិខិតបញ្ជាក់ឯកភាពរបស់សហព័ទ្ធជាពលរដ្ឋខ្មែរចំនួន ០២ច្បាប់
- ជីវប្រវត្តិសង្ខេបរបស់សមីខ្លួនមានស្នាមម្រាមដៃ ឈ្មោះ មានបិតរូបថតទំហំ ៤ ស.ម គុណ ៦ ស.ម ចំនួន ០២ ច្បាប់ និងមានភ្ជាប់រូបថតចំនួន១០សន្លឹក។ រូបថតទាំងអស់ត្រូវថតថ្មី ចំពីមុខគ្មានពាក់មួក និងគ្មានពាក់វ៉ែនតា

[62] ច្បាប់ស្តីពីសញ្ជាតិ, អនុម័តកាលពីថ្ងៃទី២១ មិថុនា ឆ្នាំ២០១៨, មាត្រា១១

[63] ច្បាប់ស្តីពីសញ្ជាតិ, អនុម័តកាលពីថ្ងៃទី២១ មិថុនា ឆ្នាំ២០១៨, មាត្រា១២

[64] អនុក្រឹត្យស្ដីពីបែបបទ និងនីតិវិធីនៃការទាមទារសញ្ជាតិខ្មែរ, មាត្រា៤

[65] អនុក្រឹត្យស្ដីពីបែបបទ និងនីតិវិធីនៃការទាមទារសញ្ជាតិខ្មែរ, មាត្រា៥

- លិខិតបញ្ជាក់ទីលំនៅ និងលិខិតបញ្ជាក់គំនិតមារយាទចេញដោយមេឃុំ ឬចៅសង្កាត់នៃទីលំនៅរបស់សមីខ្លួន ០១ ច្បាប់
- លិខិតថ្កោលទោសមានសុពលភាពចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសរបស់សមីខ្លួន ០១ ច្បាប់ ដោយមានបញ្ជាក់ពីស្ថានទូត ឬស្ថានតំណាងរបស់ខ្លួន
- សេចក្ដីចម្លងសំបុត្រអាពាហ៍ពិពាហ៍របស់សាមីខ្លួនចំនួន ០២ ច្បាប់
- លិខិតឆ្លងដែនថតចម្លងរបស់សាមីខ្លួនដែលមានសុពលភាពចំនួន ០២ ច្បាប់។

នៅពេលដែលដាក់ពាក្យទៅអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មនៃក្រសួងមហាផ្ទៃ នោះគេនឹងពិនិត្យមើលអំពីពាក្យសុំទាមទារ និងទម្រង់បែបបទរបស់ជនបរទេសនោះ។ ប្រសិនបើពាក្យសុំទាមទារ និងទម្រង់បែបបទទាំងនោះត្រឹមត្រូវហើយ នោះអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មនៃក្រសួងមហាផ្ទៃ នឹងធ្វើរបាយការណ៍មួយជូនទៅរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ស្ដីអំពីការដាក់ពាក្យស្នើសុំចូលសញ្ជាតិខ្មែរតាមរយៈការរៀបអាពាហ៍ពិពាហ៍។

ក្រោយពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានទទួល និងពិនិត្យមើលរបាយការណ៍នៃការដាក់ពាក្យសុំទាមទារនោះត្រឹមត្រូវតាមលក្ខខណ្ឌដែលបានកំណត់នៅក្នុងច្បាប់រួចហើយ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នឹងធ្វើរបាយការណ៍មួយផ្ញើរជូនទៅនាយករដ្ឋមន្ត្រី។ បន្ទាប់ពីនាយករដ្ឋមន្ត្រីបានទទួល និងពិនិត្យរបាយការណ៍ត្រឹមត្រូវចប់សព្វគ្រប់ហើយ នាយករដ្ឋមន្ត្រីនឹងធ្វើសំណើរគោរពទូលថ្វាយព្រះមហាក្សត្រ ប្រទានសញ្ជាតិឱ្យជនបរទេស។ ដូច្នេះហើយ គ្រប់ជនបរទេសដែលទទួលបានសញ្ជាតិខ្មែរ ត្រូវសម្រេចដោយព្រះរាជក្រឹត្យ[66]។ ប៉ុន្តែ ជនបរទេស ត្រូវធ្វើសម្បថនៅមុខតុលាការកំពូលសិន ទើបទទួលបានព្រះរាជក្រឹត្យ ដោយខ្លឹមសារនៃសម្បថមានចែងនៅក្នុងអនុក្រឹត្យស្ដីពីបែបបទ និងនីតិវិធីនៃការទាមទារសញ្ជាតិខ្មែរ[67]។ ចំពោះការបង់កម្រៃសេវារដ្ឋបាលក្នុងការទាមទារសញ្ជាតិខ្មែររបស់ជនបរទេសត្រូវបានកំណត់នៅក្នុងប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ[68]។

## ២.៥. ការទទួលបានការរស់នៅដោយស្របច្បាប់នៅកម្ពុជាចំពោះជនបរទេស

នាពេលបច្ចុប្បន្ននេះ នៅប្រទេសកម្ពុជាមានជនបរទេសបានចូលមកស្នាក់នៅមានការកើនឡើងគួរឱ្យកត់សម្គាល់។ គិតមកដល់ខែមិថុនា ឆ្នាំ២០២០ មានជនបរទេសប្រមាណជា ១៦ ម៉ឺននាក់ ដែលបានចុះបញ្ជីតាមប្រព័ន្ធព័ត៌មានវិទ្យាដើម្បីសុំចូលមកស្នាក់នៅក្នុងប្រទេសកម្ពុជា។ ទោះបីជាជនបរទេស មិនបានទាមទារ សុំចូលសញ្ជាតិខ្មែរតាមរយៈការរៀបអាពាហ៍ពិពាហ៍ក៏ដោយក្ដី ក៏ជនបរទេសអាចទទួលបានការរស់នៅដោយ

[66] អនុក្រឹត្យស្ដីពីបែបបទ និងនីតិវិធីនៃការទាមទារសញ្ជាតិខ្មែរ, មាត្រា៨

[67] អនុក្រឹត្យស្ដីពីបែបបទ និងនីតិវិធីនៃការទាមទារសញ្ជាតិខ្មែរ, មាត្រា៩

[68] អនុក្រឹត្យស្ដីពីបែបបទ និងនីតិវិធីនៃការទាមទារសញ្ជាតិខ្មែរ, មាត្រា៦

ស្របច្បាប់នៅកម្ពុជាបានផងដែរ។ ព្រះរាជាណាចក្រកម្ពុជាបានបែងចែកជនបរទេសដែលចូលមកដែនដីនៃប្រទេសខ្លួនជា ៣ ប្រភេទគឺ ជនអន្តោប្រវេសន៍ ជនមិនមែនអន្តោប្រវេសន៍ និងជនអន្តោប្រវេសន៍ជាអ្នកវិនិយោគឯកជន[69]។ ជនបរទេសដែលបានចូលមកប្រទេសកម្ពុជាទាំងអស់ ត្រូវបានផ្តល់សិទ្ធិមួយចំនួន និងបានហាមឃាត់នូវសិទ្ធមួយចំនួនផងដែរ។

ចំពោះជនបរទេសដែលបានចូលមកស្នាក់នៅក្នុងប្រទេសកម្ពុជា តាមរយៈការរៀបអាពាហ៍ពិពាហ៍ជាមួយនឹងពលរដ្ឋខ្មែរ ត្រូវបានចាត់ទុកជាជនអន្តោប្រវេសន៍ ដូចជនបរទេសដែលចូលមកស្នាក់នៅដោយស្របច្បាប់នៅប្រទេសកម្ពុជារយៈពេលយូរផងដែរ[70]។ ជនបរទេសដែលត្រូវក្លាយជាជនបរទេសអន្តោប្រវេសន៍ នឹងត្រូវបានទទួលស្គាល់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ[71]។

នៅពេលដែលជនបរទេស ត្រូវបានទទួលស្គាល់ជាជនបរទេសអន្តោប្រវេសន៍រួចហើយនោះ រាល់ពេលចេញចូលព្រះរាជាណាចក្រកម្ពុជា ជនអន្តោប្រវេសន៍នោះត្រូវបង្ហាញខ្លួននៅបុស្តិ៍ត្រួតពិនិត្យអន្តោប្រវេសន៍ទាំងពេលមកដល់ និងពេលចេញដំណើរទៅវិញ[72]។ ចំពោះការបង្ហាញខ្លួនរបស់ជនបរទេសអន្តោប្រវេសន៍ រាល់ក្រោយពេលមកដល់ព្រះរាជាណាចក្រកម្ពុជាត្រូវស្ថិតនៅក្នុងរយៈពេល ៤៨ ម៉ោង នឹងត្រូវបង្ហាញខ្លួននៅការិយាល័យជនបរទេសនៃស្នងការដ្ឋាននគរបាលខេត្ត ក្រុងដែលខ្លួនមានបំណងស្នាក់នៅ ដើម្បីធ្វើពាក្យសុំប័ណ្ណស្នាក់នៅ[73]។ ប័ណ្ណស្នាក់នៅត្រូវបង្ហាញនៅពេលដែលមានការឆែកឆេរពីអាជ្ញាធរមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា។

### ២.៥.១. លក្ខខណ្ឌដែលត្រូវបំពេញដើម្បីចូលមកស្នាក់នៅកម្ពុជា

ដើម្បីស្នាក់នៅកម្ពុជាដោយស្របច្បាប់បាន ជនបរទេសដែលរស់នៅកម្ពុជា តាមរយៈការរៀបអាពាហ៍ពិពាហ៍ត្រូវបំពេញនូវលក្ខខណ្ឌមួយចំនួនដូចជនមិនមែនអន្តោប្រវេសន៍ដែរ[74]។

ខាងក្រោម នេះគឺជាលក្ខខណ្ឌដែលជនបរទេសត្រូវបំពេញដើម្បីទទួលបានការស្នាក់នៅប្រទេសកម្ពុជាបានដោយស្របច្បាប់[75]៖

[69] ច្បាប់ស្តីពី អន្តោប្រវេសន៍, អនុម័តថ្ងៃទី២៦ ខែសីហា ឆ្នាំ១៩៩៤, មាត្រា៤
[70] ច្បាប់ស្តីពី អន្តោប្រវេសន៍, អនុម័តថ្ងៃទី២៦ ខែសីហា ឆ្នាំ១៩៩៤, មាត្រា១០
[71] ច្បាប់ស្តីពី អន្តោប្រវេសន៍, អនុម័តថ្ងៃទី២៦ ខែសីហា ឆ្នាំ១៩៩៤, មាត្រា១២
[72] ច្បាប់ស្តីពី អន្តោប្រវេសន៍, អនុម័តថ្ងៃទី២៦ ខែសីហា ឆ្នាំ១៩៩៤, មាត្រា១៣
[73] ច្បាប់ស្តីពី អន្តោប្រវេសន៍, អនុម័តថ្ងៃទី២៦ ខែសីហា ឆ្នាំ១៩៩៤, មាត្រា១៤
[74] ច្បាប់ស្តីពី អន្តោប្រវេសន៍, អនុម័តថ្ងៃទី២៦ ខែសីហា ឆ្នាំ១៩៩៤, មាត្រា១១
[75] ច្បាប់ស្តីពី អន្តោប្រវេសន៍, អនុម័តថ្ងៃទី២៦ ខែសីហា ឆ្នាំ១៩៩៤, មាត្រា៨

- ត្រូវមានការអនុញ្ញាតចូលជាមុនពីរាជរដ្ឋាភិបាលកម្ពុជា តាមរយៈអាជ្ញាធរទូត ឬកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា ឬតាមអាជ្ញាធរបរទេសណាមួយដែលតំណាងឱ្យផលប្រយោជន៍នៃព្រះរាជាណាចក្រកម្ពុជានៅក្រៅប្រទេស។
- ត្រូវនាំមកនូវលិខិតឆ្លងដែនរបស់ខ្លួន ឬឯកសារណាមួយដែលមានតម្លៃស្មើដែលមានចុះទិដ្ឋាការដោយអាជ្ញាធរ។
- ត្រូវបង់ថ្លៃទិដ្ឋាការ អាករព្រលានយន្តហោះ ឬកំពង់ផែ។ ការបង់នេះត្រូវកំណត់ដោយអនុក្រឹត្យ។

### ២.៥.២. កាតព្វកិច្ចដែលត្រូវបំពេញ

ក្រៅពីត្រូវបំពេញនូវលក្ខខណ្ឌ ដើម្បីទទួលបានការស្នាក់នៅដោយស្របច្បាប់ហើយនោះ ជនបរទេសអន្តោប្រវេសន៍ចាំបាច់ត្រូវបំពេញនូវកាតព្វកិច្ចមួយចំនួនបន្ថែមទៀតដូចជា[76]៖

- បង្ហាញនូវកាយសម្បទាមានផលប្រយោជន៍ដល់សេដ្ឋកិច្ច សង្គមកិច្ច វិទ្យាសាស្ត្រ បច្ចេកទេស ឬវប្បធម៌សម្រាប់ព្រះរាជាណាចក្រកម្ពុជា។
- តំកល់ប្រាក់ធានាតាមចំនួនសមស្រប សម្រាប់បង់ថ្លៃសោហ៊ុយធ្វើដំណើរត្រឡប់វិញ ឬមាតុភូមិនិវត្តន៍ជាយថាហេតុ និងត្រូវមានប្រាក់ធានាថាអាចរស់នៅបានដោយសារទ្រព្យសម្បត្តិផ្ទាល់ខ្លួន។ ចំនួនទឹកប្រាក់ខាងលើនេះត្រូវកំណត់ដោយអនុក្រឹត្យ។
- មានកាយសម្បទាបំពេញវិជ្ជាជីវៈខ្លួនបាន ដោយមានការបញ្ជាក់ពីគ្រូពេទ្យនៃប្រទេសដែលអន្តោប្រវេសន៍ចេញមក និងមានកិច្ចសន្យាការងារជាលាយលក្ខណ៍អក្សរ។
- មានលិខិតថ្កោលទោសដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសដើមរបស់ខ្លួន។
- ត្រូវបំពេញឱ្យបានលក្ខខណ្ឌផ្នែកសន្តិសុខដែលព្រះរាជាណាចក្រកម្ពុជាតម្រូវឱ្យមាន។

### ២.៥.៣. ការបណ្តេញចេញពីប្រទេសកម្ពុជា

ទោះបីជាជនបរទេសអន្តោប្រវេសន៍បានទទួលការស្នាក់នៅ ដោយស្របច្បាប់នៅព្រះរាជាណាចក្រកម្ពុជាក៏ដោយ ប៉ុន្តែ ពួកគេអាចនឹងត្រូវបានបាត់បង់នូវសិទ្ធិក្នុងការស្នាក់នៅ ប្រសិនបើពួកគេបានប្រព្រឹត្តិនូវអាកប្បកិរិយាមិនល្អដែលនាំឱ្យមានផលប៉ះពាល់ដល់ប្រទេសកម្ពុជា និងល្មើសនូវបទបញ្ញត្តិដែលប៉ះពាល់ដល់ព្រះរាជាណាចក្រកម្ពុជា។

ជនបរទេសអន្តោប្រវេសន៍ នឹងត្រូវបានបណ្តេញចេញពីប្រទេសកម្ពុជាក្នុងករណីដែល[77]៖

[76] ច្បាប់ស្តីពី អន្តោប្រវេសន៍, អនុម័តថ្ងៃទី២៦ ខែសីហា ឆ្នាំ១៩៩៤, មាត្រា១១
[77] ច្បាប់ស្តីពី អន្តោប្រវេសន៍, អនុម័តថ្ងៃទី២៦ ខែសីហា ឆ្នាំ១៩៩៤, មាត្រា៣៦

- ជនបរទេសអន្តោប្រវេសន៍នោះមានអាកប្បកិរិយា និងសកម្មភាពគ្រោះថ្នាក់ដល់សន្តិសុខជាតិនៃប្រទេសកម្ពុជា
- ក្រសួងមានសមត្ថកិច្ចមានភស្តុតាងជាក់លាក់ថាជនបរទេសអន្តោប្រវេសន៍នោះ ជាអ្នកប្រឆាំងនឹងសន្តិសុខនៃព្រះរាជាណាចក្រកម្ពុជា
- មកធ្វើការក្នុងព្រះរាជាណាចក្រកម្ពុជាដោយគ្មានប័ណ្ណការងារ
- ជាពិសេសជនបរទេសណា ដែលចូលមកប្រទេសកម្ពុជាដោយខុសច្បាប់[78]។

ជនបរទេស ដែលត្រូវបណ្តេញចេញពីព្រះរាជាណាចក្រកម្ពុជាជាសមត្ថកិច្ចរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃនឹងចេញសេចក្តីសម្រេចបណ្តេញចេញចំពោះជនបរទេសអន្តោប្រវេសន៍ណា ដែលបានរំលោភលើបញ្ញត្តិច្បាប់អន្តោប្រវេសន៍។ សេចក្តីសម្រេចបណ្តេញចេញត្រូវអនុវត្តភ្លាមក្រោយពេលចុះហត្ថលេខារបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប៉ុន្តែ សាមីខ្លួនដែលជាជនបរទេសមានសិទ្ធិប្តឹងទៅតុលាការបានក្នុងរយៈពេល ០២ ខែ។ ប្រសិនបើជនបរទេសនោះ ពុំបានប្តឹងទៅតុលាការ ដើម្បីឱ្យតុលាការចេញសាលក្រមផ្អាកការអនុវត្តការបណ្តេញចេញនោះទេ នោះការអនុវត្តការបណ្តេញចេញនឹងធ្វើឡើងក្នុងរយៈពេលយ៉ាងយូរ ០៧ ថ្ងៃក្រោយពីមានសេចក្តីសម្រេចជាផ្លូវការពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

## ២.៦. ការការពារពីការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍

នាពេលបច្ចុប្បន្ននេះ យើងឃើញថាលំហូរនៃជនបរទេសដែលមកកំសាន្ត និងចូលមកស្នាក់នៅក្នុងប្រទេសកម្ពុជាហាក់មានការកើនឡើង ដែលជាហេតុនាំឱ្យការរៀបអាពាហ៍ពិពាហ៍រវាងជនជាតិខ្មែរ និងជនបរទេសនៅកម្ពុជាមានការកើនឡើងផងដែរ។ ស្ថានភាពបែបនេះ បានបង្ហាញថាប្រទេសកម្ពុជាកំពុងតែមានភាពរីកចម្រើន ដោយត្រូវបានស្គាល់ និងមានវត្តមាននៅក្នុងឆាកអន្តរជាតិ។ ប៉ុន្តែ ការកើនឡើងនៃការរៀបអាពាហ៍ពិពាហ៍នេះ ក៏កំពុងតែបង្កើតឱ្យមានហានិភ័យចំពោះស្ត្រី ជាពិសេសស្ត្រីដែលជាអនីតិជន និងស្ត្រីដែលរស់នៅតាមតំបន់ដាច់ស្រយាល និងមានជីវភាពក្រីក្រ។ ដោយសារតែស្ថានភាពដែលជនបរទេសចូលមកប្រទេសកម្ពុជាមានការកើនឡើងបែបនេះ ជាហេតុដែលនាំឱ្យមានជនឆ្លៀតឱកាសមួយចំនួនបានប្រើប្រាស់ស្ថានភាពនេះដោយការធ្វើជាមេអណ្តើក ឬឈ្មួញកណ្តាល ហើយធ្វើការទាក់ទង អូសទាញស្ត្រីដែលមានជីវភាពលំបាកឱ្យរៀបការជាមួយនឹងជនបរទេស និងលួងលោមស្ត្រីទាំងនោះថា ពួកនាងនឹងមានជីវភាពប្រសើរបន្ទាប់ពីរៀបអាពាហ៍ពិពាហ៍ ជាដើម ដើម្បីខ្លួនទទួលបានផលប្រយោជន៍ពីការធ្វើជាឈ្មួញកណ្តាល។

[78] ច្បាប់ស្តីពី អន្តោប្រវេសន៍, អនុម័តថ្ងៃទី២៦ ខែសីហា ឆ្នាំ១៩៩៤, មាត្រា៣៧

### ២.៦.១. បញ្ហាជាក់ស្តែង

យោងតាមប្រភពព័ត៌មានពី KHMER TIMES ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២២ បានចុះផ្សាយអំពីហេតុការណ៍ដែលស្ត្រីខ្មែរកំពុងតែត្រូវបានការជួញដូរទៅប្រទេសចិនដោយការរៀបអាពាហ៍ពិពាហ៍ ដោយយោងតាមរបាយការណ៍របស់អង្គការគំនិតផ្តួចផ្តើមសកលប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន Global Initiative Again Transnational Organized Crime ("GI-TOC")។ បន្ថែមពីនេះទៀតអង្គការ GI-TOC ចំនួនស្ត្រីដែលរៀបការទៅប្រទេសចិនមានការកើនឡើងចាប់តាំងពី ២០១៦ មកម្ល៉េះ ហើយមានការកើនឡើងរឹតតែខ្លាំងចាប់តាំងពីស្ថានភាពនៃជំងឺរាតត្បាតកូវីដ១៩ បានកើតឡើង។ ទោះបីជានៅក្នុងចំណោមស្ត្រីមួយចំនួនដែលបានរៀបអាពាហ៍ពិពាហ៍ទៅប្រទេសចិនបានយល់ព្រមរៀបការទៅដោយគ្មានការបង្ខិតបង្ខំក៏ពិតមែន ប៉ុន្តែ អ្វីដែលពួកគេទទួលបានពេលទៅដល់ប្រទេសចិន គឺខុសពីការរំពឹងទុករបស់ពួកគេ ដោយសារតែពួកគេត្រូវបានរំលោភបំពានជួញដូរពីមនុស្សម្នាក់ទៅម្នាក់ទៀត ឬត្រូវបានគេយកទៅធ្វើជាទាសករ ដែលអាចស្ថិតនៅក្នុងស្ថានភាពគ្រោះថ្នាក់ណាមួយចំពោះអាយុជីវិត និងសុខភាព។

ឧទាហរណ៍ជាក់ស្តែង កាលពីខែមេសា ឆ្នាំ២០១៧ អាវុធហត្ថរាជធានីភ្នំពេញបានស្រាវជ្រាវបង្ក្រាបករណីជួញដូរមនុស្សមួយ ដែលក្រុមមេខ្យល់ដើរបោកជនរងគ្រោះថានឹងឱ្យទៅរៀបការនៅប្រទេសចិនស្របច្បាប់[79]។ ដំបូងឡើយយុវតីម្នាក់ អាយុ ១៦ ឆ្នាំ ត្រូវបានស្ត្រីម្នាក់ដែលជាជនជាតិខ្មែរបានលួងលោម ឱ្យនាងរៀបការជាមួយប្តីចិនដោយគេជាអ្នករត់ការឱ្យ។ ក្រោយពេលព្រមព្រៀង ប្អូនស្រីក៏ត្រូវស្ត្រីមេខ្យល់ម្នាក់នោះនាំមកភ្នំពេញ ជួបជាមួយស្ត្រីមេខ្យល់ម្នាក់ទៀត ដើម្បីនាំទៅធ្វើប៉ាស្ព័រ បន្ទាប់មកនាំទៅប្រទេសវៀតណាម ជួបជាមួយមេខ្យល់វៀតណាម ទើបបន្ត លួចឆ្លងដែនចូលទៅប្រទេសចិន។ ពេលទៅដល់ទឹកដីចិន ប្អូនស្រីត្រូវបានក្រុមមេខ្យល់ឃុំទុកមួយសប្តាហ៍ និងត្រូវបានមេខ្យល់លក់ឱ្យបុរសចិនពីម្នាក់ទៅម្នាក់ទៀតក្នុងតម្លៃមួយសម្រាប់រយៈពេលកំណត់មួយ ដោយលក់ឱ្យបុរសចិនទី ១ ក្នុងតម្លៃ ១២ ម៉ឺនយ៉ន់សម្រាប់រយៈពេល ០១ ខែ បន្ទាប់មកលក់ឱ្យបុរសចិនទី ២ ក្នុងតម្លៃ ១៣ម៉ឺនយ៉ន់ សម្រាប់រយៈពេល ០១ ខែកន្លះ និងលក់បន្តទៅបុរសចិនទី ៣ ក្នុងតម្លៃ ៦ ម៉ឺនយ៉ន់។ ក្រោយពេលរស់នៅជាមួយបុរសចិនទី ៣ អស់រយៈពេលប្រហែល ០២ ខែកន្លះ ប្អូនស្រីបានរកឱកាសលួចយកទូរស័ព្ទ រួចទាក់ទងមកកាន់គ្រួសារនៅឯប្រទេសខ្មែរ។ ក្រោយពីគ្រួសារប្អូនស្រីបានទទួលដំណឹងពីប្អូនស្រីភ្លាម ក៏បានពិភាក្សាគ្នារួចឡើងមកភ្នំពេញដើម្បីដាក់ពាក្យបណ្តឹង ឱ្យជួយដល់ប្អូនស្រី។ បន្ទាប់ពីបានទទួលពាក្យបណ្តឹង កងរាជអាវុធហត្ថរាជធានីភ្នំពេញបានធ្វើការស្រាវជ្រាវជាមួយក្រុមគ្រួសារជនរងគ្រោះ រហូតឈានដល់ធ្វើការឃាត់ខ្លួនមេខ្យល់ជនជាតិខ្មែរម្នាក់នៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៧។ រហូតដល់អំឡុងខែកុម្ភៈឆ្នាំ ២០១៨ កងអាវុធហត្ថរាជធានីភ្នំពេញ ទាក់ទងនារីរងគ្រោះខាងលើនៅប្រទេសចិន បានតាមរយៈទូរស័ព្ទដែល

---

[79] ខ្មែរណូត (Khmernote Media), ចុះផ្សាយថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៨

នារីរងគ្រោះលួចទំនាក់ទំនងមកដោយផ្ទាល់ និងបានណែនាំប្អូនស្រីឱ្យលួចរត់ទៅផ្លូវដែលអ៊ូអរ ដើម្បីទៅជួបជាមួយប៉ូលីសចិន ដើម្បីឱ្យប៉ូលីសជួយនាំទៅកាន់ស្ថានទូតខ្មែរប្រចាំនៅទីក្រុងប៉េកាំង។ បន្ទាប់មកអាវុធហត្ថរាជធានីភ្នំពេញ បានសហការណ៍ជាមួយនគរបាលជាតិក្រសួងមហាផ្ទៃ ក្រសួងកិច្ចការនារី គណកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ក្រសួងការបរទេស និងអង្គការសម្ព័ន្ធបានរួមគ្នាដើម្បីរៀបចំសំណុំបែបបទ និងសំបុត្រយន្តហោះដើម្បីនាំយកប្អូនស្រីរងគ្រោះពីទីក្រុងប៉េងកាំង មកកាន់កម្ពុជាវិញនៅថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៨។ នៅទីបំផុតអាវុធហត្ថរាជធានីភ្នំពេញក៏បានជួយប្អូនស្រីរួចផុតពីអំពើជួញដូរ និងទាសករផ្លូវភេទ ព្រមទាំងបានជូនប្អូនស្រីទៅដល់ស្រុកកំណើត។ ក្រោយពីប្អូនស្រីរងគ្រោះបានជួបជុំគ្រួសារនៅស្រុកកំណើតវិញ អាវុធហត្ថរាជធានីភ្នំពេញក៏បន្តនិតិវិធីដោយសហការណ៍ជាមួយអាវុធហត្ថលើផ្ទៃប្រទេស និងអាវុធហត្ថខេត្តកំពង់ចាម ធ្វើការស្រាវជ្រាវឃាត់ខ្លួនស្ត្រីមេខ្យល់ម្នាក់ទៀត នៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៨ បន្ទាប់ពីមេខ្យល់ម្នាក់នេះបានគេចខ្លួនអស់ជាច្រើនខែ និងបានបញ្ជូនទៅតុលាការដើម្បីផ្តន្ទាទោសតាមច្បាប់ នៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៨។ ជាលទ្ធផលនៃការបង្ក្រាបអំពើជួញដូរមនុស្សនេះ អាវុធហត្ថរាជធានីភ្នំពេញ បានរំដោះនារីរងគ្រោះជាអនីតិជនម្នាក់ពីប្រទេសចិនមកកាន់កម្ពុជា និងឃាត់ខ្លួនជនសង្ស័យជាមេខ្យល់បាន០២នាក់ បញ្ជូនទៅតុលាការ ព្រមទាំងកំណត់បានមុខសញ្ញាស្ត្រីខ្មែរម្នាក់ដែលមានប្តីជាជនជាតិចិន គឺជាមេក្លោងធំក្នុងការជួញដូរមនុស្សយ៉ាងសកម្មកំពុងគេចខ្លួនទៅប្រទេសចិន។

### ២.៦.២. វិធានការពារ

តាមរយៈហេតុការណ៍ដែលបានកើតឡើងជាក់ស្តែងនៅខាងលើនេះ គឺជាបទពិសោធន៍មួយដែលបានបង្ហាញឱ្យឃើញថាការរៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេស តាមរយៈឈ្មួញកណ្តាល ឬភ្នាក់ងាររើសគូរស្រករ គឺជាការប្រថុយប្រថានដ៏គ្រោះថ្នាក់បំផុតដែលគួរជៀសវាងដាច់ខាត វាអាចជាការបោកប្រាស់របស់ជនខិលខូចដើម្បីជួញដូរមនុស្ស ឬធ្វើអាជីវកម្មផ្លូវភេទទៅបរទេស ដោយពួកគេនឹងទទួលបានតម្លៃតបស្នងជាប្រាក់ ឬវត្ថុមានតម្លៃផ្សេងទៀតពីការជួញដូរទាំងនោះ។ លើសពីនេះហេតុការណ៍ដែលបានកើតឡើងខាងលើនេះ ក៏បានបង្ហាញឱ្យឃើញពីការសហការគ្នាពីសំណាក់ស្ថាប័នជាច្រើនដើម្បីសង្គ្រោះនារីខ្មែរ ដែលបានរងគ្រោះដោយសារការបោកបញ្ឆោតរបស់ឈ្មួញកណ្តាល ឬភ្នាក់ងាររើសគូរស្រករ ព្រមទាំងចាប់បានឈ្មួញកណ្តាលផ្តន្តាទោសតាមច្បាប់ផងដែរ។ ក្នុងករណីដែលមានការលួងលោម ពីសំណាក់បុគ្គលណាម្នាក់ដែលគ្មានការបញ្ជាក់ពីអាជ្ញាធរមូលដ្ឋាន គឺជាអំពើបោកបញ្ឆោត ដែលអាចឈានទៅដល់ការជួញដូរមនុស្សយ៉ាងពិតប្រាកដ។

ជាការពិតណាស់ ការឆបោក ឬលួងលោមនារីខ្មែរ តាមរយៈភ្នាក់ងាររើសគូរស្រករ ឬឈ្មួញកណ្តាលដើម្បីយកទៅធ្វើអាជីវកម្មផ្លូវភេទ ឬកេងប្រវ័ញ្ចកម្លាំងពលកម្មនៅបរទេស វាមិនមែនជាបញ្ហាថ្មីមួយនៅក្នុងសង្គមនោះទេ ប៉ុន្តែ វាបានក្លាយទៅជាបញ្ហាដ៏ក្តៅគគុកម្តងទៀតនាប៉ុន្មានឆ្នាំចុងក្រោយនេះ ជាពិសេសក្នុងកាលៈទេសៈ

